មេរៀនទី ៥

# ទេវតា៖ កងទ័ពនៃភាពងងឹត និង កងទ័ពនៃពន្លឺ

ថ្ងៃមួយខ្ញុំបានភ្ញាក់ឡើងដោយសូរសម្លេងគ្រាប់កាំភ្លើង នៅពេលដែលកងទ័ពសត្រូវធ្វើការវាយប្រហារនៅក្បែរផ្ទះរបស់ខ្ញុំ។ ប្រពន្ធរបស់ខ្ញុំ និង គ្រួសារបានស្វែងរកកន្លែងជ្រក នៅពេលមានយន្តហោះទំលាក់គ្រាប់បែកបានហោះនៅពីលើយើង។ ខ្ញុំបានឃើញទាហានដណ្តើមអាហារពីប្រជាជនស្លូតត្រង់ ។ ខ្ញុំស្អប់សង្គ្រាមណាស់!

តើអ្នកគ្រប់គ្រងដ៏ល្អ និង ឈ្លាសវៃម្នាក់គួរធ្វើអ្វី នៅពេលមានការវាយប្រហារ ពីសំណាក់ខ្មាំងសត្រូវ? ប្រសិនបើពួកគេ ពិតជាខ្វល់ខ្វាយចំពោះប្រជាជនរបស់ពួកគេ និង មាគ៌ាជីវិតដែលពួកគេបានថែរក្សា ពួកគេ*ត្រូវតែ* តតាំងជាមួយនឹងខ្មាំងសត្រូវ។ ពួកគេដឹងពីអ្វីដែលនឹងកើតឡើង ប្រសិនបើខ្មាំងសត្រូវយកឈ្នះលើពួកគេ!

បើគំនិតមួយ នេះគឺជាស្ថានភាពនៅក្នុងពិភពខាងឯវិញ្ញាណ។ កម្លាំងខាងឯវិញ្ញាណដ៏កំណាចរបស់សាតាំង តែងតែរកមធ្យោបាយបំផ្លាញ រនាំងការពាររបស់យើង ហើយសម្លាប់យើងផ្នែកខាងឯវិញ្ញាណ។ យើងនៅមានសុវត្ថិភាព ដរាបណាយើងនៅតែទុកចិត្តលើព្រះជាម្ចាស់។ កម្លាំងខាងឯវិញ្ញាណដ៏អស្ចារ្យរបស់ទ្រង់ ផ្តល់ឲ្យយើងនូវការជំនួយ នៅក្នុងការតតាំងជាមួយអារក្ស ដែលជាខ្មាំងសត្រូវរបស់យើងនោះ។ ដូច្នេះសង្គ្រាមខាងឯវិញ្ញាណ បង្កើតបានជាមូលដ្ឋានគ្រឹះផ្ទុយនឹងអ្វីដែលយើងសិក្សាអំពីទេវតា។

នៅក្នុងជំពូកទី១ យើងបានរៀនអំពីព្រះជាម្ចាស់ និង ការគ្រប់គ្រងជាអធិបតី របស់ទ្រង់នៅក្នុងសាកលលោកនេះហើយ។ ឥឡូវនេះយើង ងាកទៅរកអនុរាស្ត្រដែលស្ថិតក្រោមការគ្រប់គ្រងដ៏ខ្ពស់បំផុតរបស់ទ្រង់ គឺទេវតា មនុស្ស និង បញ្ហានៃអំពើបាបវិញម្តង។ នៅក្នុងមេរៀនទាំងបីបន្ទាប់នេះ យើងនឹងមិនត្រឹមតែបានឃើញពីមូលហេតុនៃអំពើបាបនោះទេ ប៉ុន្តែយើងក៏បានឃើញពីផលវិបាកដ៏ធំធេងរបស់អំពើបាបទៅលើអនុរាស្ត្រទាំងអស់របស់ព្រះជាម្ចាស់ផងដែរ។

ក្នុងពេលដែលយើងសិក្សាមេរៀននេះ អំពីព្រះមហាក្សត្រ និង កម្លាំងនៃទេវតា ដែលទ្រង់អាចប្រើតាមបំណងព្រះទ័យរបស់ទ្រង់ ខ្ញុំសូមអធិស្ឋានឲ្យអ្នកបាន យល់ដឹកកាន់តែច្បាស់ថែមទៀតនៅពេលដែលអ្នកដឹងថា ទ្រង់កំពុងតែដឹកនាំមនុស្សដែលទទួលបានការប្រោសលោះជាច្រើននាក់ ឆ្ពោះទៅកាន់ជ័យជម្នះចុងក្រោយបំផុត។

## គម្រោងមេរៀន

ក. និស្ស័យរបស់ទេវតា
ខ. លក្ខណសម្បត្តិខាងឯសីលធម៌របស់ទេវតា
គ. ចំនួនរបស់ទេវតា
ឃ. ការរៀបចំនិងសកម្មភាពរបស់ទេវតា

## វត្ថុបំណងមេរៀន

នៅពេលដែលអ្នកបញ្ចប់មេរៀននេះ អ្នកអាចនឹង៖

១. ប្រាប់ពីដើមកំណើត និង លក្ខណសម្បត្តិរបស់ទេវតា។
២. រៀបរាប់ពី លក្ខណសម្បត្តិខាងឯសីលធម៌របស់ទេវតា ដោយប្រើប្រាស់ខគម្ពីរធ្វើជាមូលដ្ឋាន។
៣. សង្ខេបសេចក្ដីបង្រៀននៅក្នុងព្រះគម្ពីរ ដែលទាក់ទងនឹងចំនួនរបស់ទេវតា។
៤. បង្ហាញភស្តុតាងនៃ សកម្មភាពដែលបានរៀបរបស់ចំពួកទេវតាដ៏វិសុទ្ធ។
៥. រៀបរាប់អំពីសកម្មភាព និង វាសនាពួកទេវតាមិនវិសុទ្ធ និង អ្នកដឹកនាំរបស់ពួកគេ។

## សកម្មភាពនៅក្នុងការសិក្សា

១. សម្រាប់គ្រឹះមូលដ្ឋាននៃមេរៀននេះ ចូរអានគម្ពីរអេភេសូ ៦:១០-១៨ គម្ពីរ២ពេត្រុស ២:១-២២ និង គម្ពីរយូដាស។
២. ការសិក្សាមេរៀនដោយផ្អែកទៅលើក្បួនដែលបានផ្ដល់ជូននៅក្នុងមេរៀនទី១។ មានខគម្ពីរយោងច្រើន ដែលមានសារៈសំខាន់ដើម្បីស្វែងយល់អំពីមេរៀននេះ ។ ត្រូវតែធ្វើឲ្យប្រាកដថា អ្នកបានអានខគម្ពីរយោងទាំងអស់នោះ ហើយឆ្លើយនឹងសំណួរនៅក្នុងមេរៀនទាំងអស់។ បន្ទាប់មកធ្វើការប្រឡងផ្ទាល់ខ្លួនដូចធម្មតា។

## ពាក្យសំខាន់ៗ

| | | |
|---|---|---|
| បច្ចាមិត្ត | កំណាច | សមហេតុផល |
| ភ្នាក់ងារ | មហន្តរាយ | អាណាចក្រ |
| ទទួលយក | ការសរសើរតម្កើង | ការបះបោរ |
| ឋានអាទិទេព | ក្លែងខ្លួន | អនុរាស្ត្រ |
| អះអាងបញ្ជាក់ | ការអន្តរាគមន៍ | កំពូលមនុស្ស |
| ជោគវាសនា | ការពិសោធន៍មើល | |

# ក. និស្ស័យរបស់ទេវតា

អ្នកនិពន្ធគម្ពីរហេប្រឺបានណែនាំយ៉ាងដូច្នេះថា៖ "សូមកុំភ្លេចទទួលអ្នកដទៃយ៉ាងរាក់ទាក់។ ដោយទទួលអ្នកដទៃដូច្នេះ អ្នកខ្លះបានទទួលទេវតា*ទាំងមិនដឹងខ្លួន។" (គម្ពីរហេប្រឺ ១៣:២)។

នៅក្នុងការនិយាយអំពីទេវតាត្រង់នេះ យើងឃើញអ្វីម្យ៉ាងអំពីនិស្ស័យរបស់ពួកគេ ដ្បិតពួកគេគឺអស្ចារ្យណាស់។ ដោយសារតែភាពមិនធម្មតារបស់ពួកគេនេះហើយ ទើបធ្វើឲ្យមានអាថ៌កំបាំងជាច្រើនដែលទាក់ទងនឹងពួកគេ។ ការពិតមួយនេះត្រូវបានបង្ហាញម្ដងហើយម្ដងទៀតទាំងនៅក្នុងបទគម្ពីរសម្ព័ន្ធមេត្រីចាស់ និង គម្ពីរសម្ព័ន្ធមេត្រីថ្មី។

យើងមិនអាចអានបទគម្ពីរដោយគ្មានការសង្កេតឃើញថា ខគម្ពីរទាំងនោះបានគាំទ្រអត្ថិភាពរបស់ពួកទេវតា។ តើយើងអាចដឹងអ្វីខ្លះពីព្រះគម្ពីរទាក់ទងនឹងពួកទេវតា? តើពួកគេមានដើមកំណើតមកពីណា? តើពួកគេមានលក្ខណសម្បត្តិយ៉ាងដូច្នេះ? ការស្វែងរកចម្លើយសម្រាប់សំណួរទាំងនេះ នឹងជួយឲ្យយើងបានយល់បន្ថែមទៀតអំពីគោលបំណងសម្រាប់ពួកទេវតា និង សារៈសំខាន់របស់ពួកគេនៅក្នុងជីវិតរបស់យើង។ ចូរសិក្សាអំពីការពិតខ្លះៗដែលព្រះគម្ពីរបានលើកឡើង ទាក់ទងនឹងដើមកំណើត (ការចាប់ផ្ដើម) និង លក្ខណសម្បត្តិរបស់ពួកទេវតា។

## ដើមកំណើតរបស់ពួកគេ

**វត្ថុបំណងទី១.** *ប្រាប់ពីដើមកំណើត និង លក្ខណសម្បត្តិរបស់ទេវតា។*

*តើទេវតាគឺជាអ្វី?* ពួកទេវតាគឺជាចំណែកមួយ ឬ ក្រុមមានដែនកំណត់មួយ នៃភាវៈដែលត្រូវបានបង្កើតឡើងឲ្យធ្វើជាអ្នកនាំសារ ឬ អ្នកបម្រើរបស់ព្រះជាម្ចាស់។ ពួកគេមានសតិបញ្ញា និង ឫទ្ធានុភាពអស្ចារ្យជាងមនុស្ស។ មានទេវតាខ្លះបម្រើបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់នៅក្នុងរបៀបវិជ្ជមានមួយតាមរយៈពួកវិសុទ្ធរបស់ពួកគេ និង ដោយស្ម័គ្រចិត្តធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ចំណែកឯពួកទេវតាខ្លះទៀត ដែលបានបះបោរប្រឆាំងនឹងព្រះជាម្ចាស់ ជាលទ្ធផលពួកគេបានដាច់ចេញពីព្រះជាម្ចាស់ជារៀងរហូត។ ការដាច់ចេញអស់កល្បជានិច្ចពីព្រះជាម្ចាស់ បង្ហាញយ៉ាងច្បាស់ពីព្រះគុណរបស់ព្រះជាម្ចាស់ចំពោះមនុស្សជាតិមានបាប ដែលទទួលបានការសង្គ្រោះតាមរយៈព្រះគ្រិស្ត។

ពាក្យថា *ទេវតា* តាមភាសាព្រះគម្ពីរដើមដំបូងបង្អស់ គឺមានន័យថា *អ្នកនាំសារ*។ ពេលខ្លះពាក្យថា *អ្នកនាំសារ* ត្រូវបានគេប្រើប្រាស់ដើម្បីនិយាយសំដៅទៅលើ មនុស្ស (បូជាចារ្យម្នាក់នៅក្នុងគម្ពីរម៉ាឡាគី ២:៧) ឬ ត្រូវបានប្រើប្រាស់ដើម្បី ធ្វើជាតំណាងឲ្យរបស់ដែលអរូប (ខ្យល់នៅក្នុងគម្ពីទំនុកតម្កើង ១០៤:៤)។ ដោយសារតែពាក្យនេះត្រូវបានគេប្រើប្រាស់តាមរបៀបខុសៗគ្នា យើងត្រូវគិតពិចារណាទៅលើបរិបទនៅក្នុងករណីនីមួយៗដើម្បីកំណត់ថាតើមួយណាជាអត្ថន័យត្រឹមត្រូវ។ ជាទូទៅ ទោះជាយ៉ាងណាក្ដី នៅពេលដែលព្រះគម្ពីរថែងអំពីពួកទេវតា គឺតែងតែសំដៅទៅលើភាវៈខាងឯវិញ្ញាណ និង និង អធិធម្មជាតិដែលត្រូវបានបង្ហាញថាជាអ្នកនាំសារពិសេសរបស់ព្រះជាម្ចាស់។

*តើពួកទេវតាទាំងនោះមកពីកន្លែងណា?* អ្នកនិពន្ធគម្ពីរទំនុកតម្កើង ពោលថា ទេវតា និង អ្វីៗដែលស្ថិតនៅឋានអាទិទេព រួមជាមួយនឹងព្រះអាទិត្យ ព្រះច័ន្ទ និង ផ្កាយគឺសុទ្ធតែត្រូវបានបង្កើតដោយព្រះជាម្ចាស់ (គម្ពីរទំនុកតម្កើង ១៤៨:២-៥)។ លោកយ៉ូហាន បានបន្ថែមឃ្លាមួយកាន់តែពេញលេញ អំពីកិច្ចការ

បង្កើតរបស់ព្រះគ្រិស្ត ៖ "សព្វសារពើសុទ្ធតែកើតឡើងដោយសារព្រះបន្ទូល គឺក្នុងបណ្តាអ្វីៗដែលកើតមក គ្មានអ្វីមួយកើតមកក្រៅពីព្រះអង្គបង្កើតនោះឡើយ។" (គម្ពីរយ៉ូហាន ១:៣)។ ដោយសារតែបទគម្ពីរបាន សន្មតយ៉ាងជាក់លាក់ថា អត្ថិភាពនៃអ្វីៗគ្រប់បែបយ៉ាងគឺជារបស់ព្រះជាម្ចាស់ នោះយើងដឹងថាពួកទេវតា ក៏ជាភាវៈដែលត្រូវបានព្រះជាម្ចាស់បង្កើតឡើងផងដែរ។ បទគម្ពីរខាងក្រោម បង្ហាញឲ្យយើងឃើញកាន់តែ ច្បាស់ថែមទៀត។

## លំហាត់អនុវត្តន៍

១ ចូរបំពេញប្រយោគខាងក្រោមនេះ។

ក) គម្ពីរកូឡុស១:១៦ ថ្លែងថា ព្រះអម្ចាស់យេស៊ូគ្រិស្តនៃយើង បានបង្កើត.................................... ..............................................................................(បូករួមទាំងពួកទេវតាផងដែរ)។

ខ) នៅក្នុងគម្ពីរ១ធីម៉ូថេ ៦:១៣-១៦ យើងបានដឹងថា ព្រះជាម្ចាស់តែមួយគត់ដែលបានប្រទាន ...................................ឲ្យអ្វីគ្រប់យ៉ាង។ (បូករួមទាំងពួកទេវតាផងដែរ)។

យើងមិនបានដឹងថាពួកទេវតាត្រូវបានបង្កើតឡើង នៅពេលណាឲ្យជាក់លាក់នោះទេ ព្រោះព្រះ គម្ពីរមិនបានបង្ហាញពីពេលវេលានោះទេ។ យើងបានត្រឹមតែដឹងថា ការបង្កើតពួកទេវតាគឺមុនព្រឹត្តិការណ៍ ដែលមានកត់ត្រានៅក្នុងគម្ពីរលោកុប្បត្តិជំពូក៣ទៅទៀត ព្រោះត្រង់ចំណុចនោះ គឺជាពេលសាតាំងដែល ជាទេវតាមួយរូប បានមកមានទំនាក់ទំនងជាមួយមនុស្សជាតិ។ ក្នុងពេលជាមួយភាវៈប្រកបដោយ ពិចារណញាណ (ការគិត) ដែលព្រះជាម្ចាស់បង្កើត ពួកទេវតាទទួលបានភាពអមតៈ នោះមានន័យថា ពួកគេនឹងមិនបាត់ទៅណាឡើយ (គម្ពីរលូកា ២០:៣៦)។

## លំហាត់អនុវត្តន៍

២ យោងតាមភស្តុតាងនៅក្នុងព្រះគម្ពីរ ទាក់ទងនឹងដើមកំណើតរបស់ពួកទេវតា យើងអាច សន្និដ្ឋានបានថា ពួកគេគឺជា

ក) ភាវៈមានជីវិតអមតៈ ដែលមានអត្ថិភាពតាំងពីដើមរៀងមក។

ខ) ភាវៈមានជីវិតអមតៈ ដែលនឹងមិនបាត់ទៅណានោះទេ។

គ) ភាវៈមានជីវិតអាចស្លាប់ដូចជាមនុស្ស ប៉ុន្តែមានឫទ្ធានុភាព និង ប្រាជ្ញាខ្ពង់ខ្ពស់ជាង។

ឃ) ជាអំបូរនៃភាវៈមួយដែលស្រដៀងនឹងព្រះជាម្ចាស់ដែរ។

# លក្ខណសម្បត្តិរបស់ពួកគេ

នៅក្នុងការពិភាក្សាអំពីដើមកំណើតរបស់ពួកទេវតា យើងបានសំគាល់ឃើញពីលក្ខណសម្បត្តិមួយរបស់ពួកគេ៖ ពួកគេគឺ*ត្រូវបានបង្កើត*។ លក្ខណសម្បត្តិមួយចំនួនទៀតក៏ លេចមកឲ្យយើងឃើញ នៅពេលដែលយើងសិក្សាអំពីបទគម្ពីរ។

ពួកទេវតាគឺជា*ភាវៈខាងឯវិញ្ញាណ*។ គម្ពីរហេប្រឺ ១:១៤ បានថ្លែងថា៖ "ទេវតាទាំងនោះសុទ្ធតែជាវិញ្ញាណ ដែលនៅបំរើព្រះជាម្ចាស់ ព្រះអង្គចាត់ពួកលោកអោយមកបំពេញមុខងារ ជាប្រយោជន៍ដល់អស់អ្នកដែលត្រូវទទួលការសង្គ្រោះទុកជាមត៌ក!" ពួកមនុស្សមិនត្រូវបានរៀបរាប់ថា ជា*វិញ្ញាណ*នោះទេ ដ្បិតពួកគេមាននិស្ស័យពីរយ៉ាង៖ ខាងរូបី(សាច់ឈាម) និង ខាងអរូបី (វិញ្ញាណ)។ ដោយសារតែពួកទេវតាគឺជា*វិញ្ញាណ* យើងមិនអាចចាត់ទុកពួកគេថាមានរូបកាយបាននោះទេ។ រឿងនេះគឺជារឿងដែលជាប់ពាក់ព័ន្ធនឹងគម្ពីរអេភេសូ ៦:១២៖ "ដ្បិតយើងមិនមែនតយុទ្ធទល់នឹងមនុស្សទេ គឺតយុទ្ធទល់នឹង.......ឥទ្ធិពលអរូបដ៏អាក្រក់ទាំងឡាយដែលនៅស្ថានលើដែរ។" ខគម្ពីរនេះនិយាយសំដៅទៅលើពួកទេវតាអាក្រក់ដែលធ្វើការឲ្យសាតាំង។

ខគម្ពីរបានបង្ហាញថា ពួកទេវតាតែងតែបានបង្ហាញខ្លួន ក្នុងទម្រង់ជាមនុស្ស (គម្ពីរចៅហ្វាយ ៦:១១-២៤ គម្ពីរយ៉ូហាន ២០:១២) ប៉ុន្តែការលេចឡើងមិនធម្មតានេះ មិនមានន័យថាពួកគេមានខ្លួនប្រាណជាផ្នែកសំខាន់ចាំបាច់នៅក្នុងអត្ថិភាពរបស់ពួកគេនោះទេ។ ផ្ទុយទៅវិញ ពួកគេ*ទទួលយក*សណ្ឋានដែលមានខ្លួនប្រាណ នៅក្នុងពេលខ្លះ ដើម្បីជាប្រយោជន៍សម្រាប់ពួកគេធ្វើទំនាក់ទំនងជាមួយមនុស្ស។ ដោយពួកគេគ្មានខ្លួនប្រាណខាងឯសាច់ឈាម ជាផ្នែកចាំបាច់នៃអត្ថិភាពរបស់ពួកគេ នោះពួកទេវតាមិនស្គាល់សោះឡើយ ថាអ្វីជាការលូតលាស់ ភាពចាស់ និង សេចក្តីស្លាប់។

ពួកទេវតាគឺជា*ភាវៈដែលមានលក្ខណៈជាបុគ្គល*។ ពួកគេបង្ហាញឲ្យឃើញពីផ្នែកមូលដ្ឋានចម្បង នៃបុគ្គលិកលក្ខណៈ៖ សតិបញ្ញា អារម្មណ៍ និង ឆន្ទៈ។ ចំណេះដឹងខ្លះៗអំពីសមត្ថភាពខាង*សតិបញ្ញា*របស់ពួកទេវតា ដែលមនុស្សជំនាន់សម័្ពន្ធមេត្រីចាស់សង្កេតឃើញ ត្រូវបានលើកនៅក្នុងគម្ពីរ២សាំយូអែល ១៤:២០។ គម្ពីរលូកា៤:៣៤ បង្ហាញថាសូម្បីតែពួកទេវតាអាក្រក់ក៏មានវិសាលភាពនៃចំណេះដឹងខ្ពង់ខ្ពស់ជាងមួយមនុស្សទៅទៀត។ គម្ពីរវិវរណៈ ១២:១២ បង្ហាញយើងអំពីសមត្ថភាពរបស់ពួកទេវតាអាក្រក់ ក្នុងការបង្ហាញ*អារម្មណ៍* (ភាពឃោរឃៅ ឬកំហឹង) ។ ព្រះយេស៊ូមានព្រះបន្ទូលអំពីការបង្ហាញអារម្មណ៍ដ៏រីករាយរបស់ពួកទេវតាដ៏វិសុទ្ធ (អំណរ) នៅក្នុងគម្ពីរលូកា ១៥:១០។ លោកប៉ូលបាននិយាយអំពីសមត្ថភាពរបស់អារក្សក្នុងការ ដាក់អន្ទាក់មនុស្ស ដើម្បីឲ្យពួកគេធ្វើតាម *ចិត្ត*របស់វា (គម្ពីរ២ធីម៉ូថេ ២:២៦)។ ទាំងនេះគ្រាន់តែជាឧទាហរណ៍បន្តិចបន្តួចនៃខគម្ពីរដែលនិយាយអំពីនិស្ស័យជាបុគ្គលរបស់ពួកទេវតា។

ពួកទេវតា *គ្មានភេទ* នោះទេ។ ពួកគេមិនត្រូវបានបែងចែក ដោយយោងទៅតាមភេទរបស់ពួកគេនោះទេ ទោះបីជាមានទេវតាខ្លះទទួលបានឈ្មោះបែបមនុស្សប្រុស (កាព្រីយ៉ែល និង មីកែល)។ ព្រះគម្ពីរបានថ្លែងថា ពួកទេវតាមិនរៀបការប្តីប្រពន្ធនោះទេ (គម្ពីរម៉ាថាយ ២២:៣០) ។ ដោយសារតែពួកទេវតាមិនអាចបន្តពូជដោយខ្លួនឯងបាន យើងអាចនិយាយយ៉ាងត្រឹមត្រូវថា ពួកគេគឺជាក្រុមមួយ ហើយមិនមែនជាពូជអំបូរមួយនោះទេ។ អ្នកប្រហែលជាបានសំគាល់ឃើញថា ស្របពេលដែលបទគម្ពីរបាននិយាយនៅ

ក្នុងគម្ពីរសម្ព័ន្ធមេត្រីចាស់ថា ពួកទេវតាគឺជា *បុត្ររបស់ព្រះជាម្ចាស់* តែមិនដែលនិយាយអំពី*កូនរបស់ពួកទេវតានោះទេ* (សូមមើលគម្ពីរយ៉ូប ១:៦; ២:១; ៣៨:៧)។

ដូចដែលយើងបានសំគាល់ឃើញហើយថា ពួកទេវតាមានសតិបញ្ញាលើសពីមនុស្ស ។ ព្រះយេស៊ូបានមានព្រះបន្ទូលថា ប្រាជ្ញាញាណរបស់ពួកគេគឺធំធេងណាស់៖ "រីឯថ្ងៃកំណត់ និងពេលវេលា គ្មាននរណាដឹងឡើយ *ទោះបី*ទេវតា*នៅស្ថានបរមសុខ* ឬព្រះបុត្រាក៏ពុំជ្រាបដែរ មានតែព្រះបិតាមួយព្រះអង្គប៉ុណ្ណោះដែលជ្រាប។" (គម្ពីរម៉ាថាយ ២៤:៣៦ )។ ប៉ុន្តែទោះបីជាចំណេះដឹងរបស់ពួកគេលើសពីមនុស្សយ៉ាងណាក្តី ក៏នៅតែមានកំណត់។ លោកពេត្រុស បានមានប្រសាសន៍ នៅក្នុងការរៀបរាប់ពីសិរីរុងរឿងដែលនឹងមកតាមក្រោយ ថា៖ "សូម្បីតែពួកទេវតា* ក៏ប្រាថ្នាចង់យល់ជំរៅនៃសេចក្តីទាំងនោះដែរ"។ (គម្ពីរ ១ពេត្រុស ១:១២)។

ការសិក្សាស៊ីជម្រៅអំពីលក្ខណសម្បត្តិរបស់ពួកទេវតា នាំឲ្យយើងសន្និដ្ឋានបានថា *ឫទ្ធានុភាព*របស់ពួកគេគឺ ត្រូវបានបញ្ជាក់ច្បាស់ជាងលក្ខណសម្បត្តិដទៃផ្សេងទៀត។ លោកពេត្រុសសង្កេតឃើញថា ពួកទេវតាគឺមានឫទ្ធានុភាពខ្លាំងក្លាជាងមនុស្ស (គម្ពីរ២ពេត្រុស ២:១១) ។ អ្នកនិពន្ធទំនុកតម្កើងបានចាត់ទុកទេវតាជា "អ្នកដែលមានឥទ្ធិឫទ្ធិខ្លាំង ហើយក៏ប្រតិបត្តិតាមបង្គាប់ទ្រង់ ដោយស្តាប់តាមព្រះសូរសៀងនៃព្រះបន្ទូលទ្រង់" (គម្ពីរទំនុកតម្កើង ១០៣:២០, ពគប១៩៥៤)។ លោកប៉ូលបានចាត់ទុកពួកគេថា ជា "ពួកទេវតានៃព្រះចេស្តាទ្រង់" (គម្ពីរ២ថែស្សាឡូនិក ១:៧,ពគប១៩៥៤) ។

នៅក្នុងករណីទេវតាអាក្រក់ (ដែលយើងនឹងវិភាគនៅពេលក្រោយ) ក៏ដូចគ្នាដែរ ។ ឫទ្ធានុភាព គឺនៅតែជាលក្ខណសម្បត្តិដែល ត្រូវបានបញ្ជាក់ច្បាស់ៗ៖ "ចៅហ្វាយរបស់លោកីយ៍នេះ" (គម្ពីរយ៉ូហាន ១២:៣១,ពគប ១៩៥៤) "មនុស្សខ្លាំងពូកែ" (គម្ពីរលូកា១១:២១,ពគប ១៩៥៤) "អំណាចនៃសេចក្តីងងឹត" (គម្ពីរលូកា២២:៥៣,ពគប ១៩៥៤) "ពួកម្ចាស់នៃសេចក្តីងងឹតនៅលោកីយ៍នេះ" (គម្ពីរអេភេសូ៦:១២, ពគប ១៩៥៤ "ឫទ្ធិអំណាចគ្រប់យ៉ាងរបស់មារសត្រូវ" (គម្ពីរលូកា ១០:១៩) ។ នៅពេលដែលសាតាំងល្បួងព្រះយេស៊ូ វាបានបង្ហាញព្រះយេស៊ូគ្រប់នគរទាំងអស់នៅក្នុងលោកីយ៍ ហើយបាននិយាយថា៖ "ខ្ញុំនឹងប្រគល់អំណាច ព្រមទាំងភោគទ្រព្យរបស់នគរទាំងនោះអោយលោក ដ្បិតអ្វីៗទាំងអស់ជាសម្បត្តិរបស់ខ្ញុំ ខ្ញុំអាចប្រគល់អោយអ្នកណាក៏បានស្រេចតែនឹងចិត្តខ្ញុំ។" (គម្ពីរលូកា ៤:៦)។

ប៉ុន្តែទោះបីជាប្រាជ្ញានិង ឫទ្ធានុភាពរបស់ពួកគេលើសពីមនុស្សយ៉ាងណាក្តី *លក្ខណសម្បត្តិទាំងនេះរបស់ពួកទេវតានៅតែមានដែនកំណត់។* គ្រាន់តែទេវតាតែម្នាក់ប៉ុណ្ណោះ ក៏អាចចាប់សាតាំងចង ហើយបោះវាទៅក្នុង រណ្តៅគ្មានបាត នៅគ្រាចុងក្រោយបានដែរ (គម្ពីរវិវរណៈ ២០:២-៣) ។ ប៉ុន្តែមុននឹងគ្រានៃការឃុំឃាំងនោះមកដល់ សាតាំង និង ទេវតារបស់វា នឹងត្រូវតយុទ្ធជាមួយទេវតាមីកែលដែលជាមហាទេវតាម្នាក់ និង ពួកទេវតារបស់លោក។ សាតាំងនឹងចាញ់សង្គ្រាមនៅស្ថានលើ ហើយនឹងត្រូវបណ្តេញចេញ (គម្ពីរវិវរណៈ ១២:៧-៩) ។ យោងតាមគម្ពីរដានីយ៉ែលជំពូក១០ ទេវតាល្អ និង ទេវតាអាក្រក់មានជម្លោះជាមួយគ្នាដោយសារតែរឿងមនុស្ស និង ប្រជាជាតិ។ ទាំងទេវតាមីកែលដែលជាមហាទេវតា (គម្ពីរយូដាស ៩ ) ឬ សាតាំង (យ៉ូប ១-២) អំណាចរបស់ពួកគេសុទ្ធតែមានកម្រិត។

ភស្តុតាងមួយអំពីភាពមានកម្រិតរបស់ពួកទេវតា គឺឃើញមាននៅក្នុងការពិតដែលថា *ពួកគេមិនមានសព្វដ្ឋភាព(សព្វវត្តមាន,សព្វត្ថិភាព)នោះទេ។* សាតាំងបានទូលតបទៅនឹងសំណួររបស់ព្រះជាម្ចាស់ទាក់ទងនឹងសកម្មភាពរបស់វា ថា៖ "មកពីដើរចុះឡើងទៅមកនៅផែនដី" (គម្ពីរយ៉ូប១:៧ពគប១៩៥៤ ហើយសូមមើលគម្ពីរ១ពេត្រុស៥:៨)។ ពួកទេវតារបស់ព្រះអម្ចាស់ទូលទ្រង់ថាពួក "យើងខ្ញុំបានធ្វើដំណើរឆ្លងកាត់ផែនដី" (គម្ពីរសាការី១:១១) ។ ចលនាទាំងពីកន្លែងមួយទៅកន្លែងមួយទាំងអស់នេះ គឺត្រូវការពេលវេលា ហើយមានពេលខ្លះ ត្រូវបានពន្យារពេលផងដែរ (គម្ពីរដានីយ៉ែល ១០:៥,១២-១៤) ។ ភាពមានដែនកំណត់នេះ ក៏ជាមូលហេតុធ្វើឲ្យ ចម្បាំងខាងឯវិញ្ញាណដែលមនុស្សរបស់ព្រះជាម្ចាស់ច្បាំង តែងតែបន្តអស់រយៈជាយូរ។

ចុងក្រោយយើងត្រូវយល់ថា *ទេវតាមិនមែនជាមនុស្សបានសិរីល្អនោះទេ ។* ព្រះគម្ពីរបានធ្វើការបែងចែករវាង "ពួកទេវតាទាំងសល់សែន" និង "វិញ្ញាណនៃពួកសុចរិត ដែលបានគ្រប់លក្ខណ៍" នៅក្នុងក្រុងយេរូសាឡឹមនៃស្ថានបរមសុខ (គម្ពីរហេប្រឺ ១២:២២-២៣ *ពគប១៩៥៤*) ភាពដោយឡែកគ្នានេះ ត្រូវបានគេឃើញមាននៅក្នុងគម្ពីរហេប្រឺ ២:១៦៖ "ព្រះយេស៊ូពិតជាពុំបានយាងមកជួយពួកទេវតា*ទេ គឺព្រះអង្គមកជួយពូជពង្សរបស់លោកអប្រាហាំវិញ។"

តាមពិតទៅ យើងមាន "ឋានៈទាបជាងទេវតាតែបន្តិច" ក្នុងមួយរយៈពេលខ្លីប៉ុណ្ណោះ(គម្ពីរទំនុកតម្កើង៨:៤-៥) ប៉ុន្តែនៅក្នុងថ្ងៃអនាគត យើងនឹងបានខ្ពស់ជាង (គម្ពីរហេប្រឺ ២:៧) ។ លោកប៉ូលមានប្រសាសន៍ថា៖ "សូម្បីតែពួកទេវតា* ក៏យើងវិនិច្ឆ័យទោសទៅហើយ"។ នៅក្នុងការវិនិច្ឆ័យទោសនេះ យើងដឹងថាអ្នកដែលតូចទាប ឬ មានឋានៈក្រោម មិនអាចវិនិច្ឆ័យទោសអ្នកដែលមានឋានៈខ្ពស់ជាងបានឡើយ។

## លំហាត់អនុវត្តន៍

៣ ចូរប្រាប់របៀបបីយ៉ាង ដែលថាលក្ខណសម្បត្តិរបស់ទេវតាមានដែនកំណត់

............................................................................................................................................

............................................................................................................................................

............................................................................................................................................

៤ ចូរផ្គូផ្គងលក្ខណសម្បត្តិរបស់ពួកទេវតា (ខាងស្តាំ) ទៅជាមួយនឹងការរៀបរាប់ដែលត្រឹមត្រូវ (ខាងឆ្វេង)។

| | |
|---|---|
| .........ក) មិនអាចបន្តពូជ ឬបង្កើនចំនួនដោយខ្លួនឯងបាន | ១) ត្រូវបានបង្កើតឡើង<br>២) ជាវិញ្ញាណ |
| .........ខ) អាចនៅកន្លែងតែមួយក្នុងពេលតែមួយ | ៣) មានភាពជាបុគ្គល |
| .........គ) អាចបំពេញតាមបំណងព្រះហឫទ័យ និង ការសម្រេចព្រះទ័យអ្នកដឹកនាំរបស់ពួកគេ។ | ៤) គ្មានភេទ<br>៥) មានសតិបញ្ញា<br>៦) មានឫទ្ធានុភាពខ្ពស់ |
| ........ឃ) មានចំណេះដឹងអំពីរឿងរ៉ាវរបស់មនុស្ស។ | ៧) គ្មានសព្វដ្ឋភាព(សព្វត្ថិភាព) |

.......ង) គ្មានរូបរាងសាច់ឈាមនោះទេ។

.......ច) បានកើតឡើងនៅក្នុងពេលវេលាជាក់លាក់មួយសិរីល្អនោះទេ។

........ឆ) ត្រូវបានបែងចែកយ៉ាងច្បាស់នៅក្នុងបទគម្ពីរឲ្យដាច់ពីមនុស្ស។

........ជ) មានសតិបញ្ញា អារម្មណ៍ និង ឆន្ទះ

៨) មិនមែនជាមនុស្សដែលបានណាមួយ។

# ខ. លក្ខណសម្បត្តិខាងឯសីលធម៌របស់ទេវតា

## ទេវតាត្រូវបានបង្កើតមកឲ្យមានភាពវិសុទ្ធ

**វត្ថុបំណងទី២.** *រៀបរាប់ពី លក្ខណសម្បត្តិខាងឯសីលធម៌របស់ទេវតា ដោយប្រើប្រាស់ខគម្ពីរធ្វើជាមូលដ្ឋាន។*

យើងបាននិយាយអំពីទេវតាដ៏វិសុទ្ធ ព្រមទាំងទេវតាអាក្រក់ផងដែរ។ ការសិក្សារបស់យើងនៅក្នុងផ្នែកនេះ នឹងបង្ហាញថា ទេវតាទាំងអស់ត្រូវបានមកឲ្យមានភាពវិសុទ្ធ ប៉ុន្តែមានទេវតាខ្លះបានធ្លាក់ចេញពីភាពវិសុទ្ធរបស់ពួកគេ ហើយដោយសារតែការមានកំហុសរបស់ពួកគេនេះហើយ ក៏បណ្តាលឲ្យមានផលលំបាកយ៉ាងធ្ងន់ធ្ងរចំពោះសាកលលោកទាំងមូល។

ព្រះគម្ពីរបាននិយាយតែបន្តិចបន្តួចតែប៉ុណ្ណោះអំពីសភាពដើមរបស់ពួកទេវតា ប៉ុន្តែយើងបានដឹងហើយថា នៅចុងបញ្ចប់នៃសកម្មភាពនៃការបង្កើតរបស់សព្វសារពើ "ព្រះជាម្ចាស់ទតឃើញអ្វីៗទាំងអស់ដែលព្រះអង្គបានបង្កើតមក ព្រះអង្គឈ្វេងយល់ថាល្អប្រសើរបំផុតហើយ"។ (គម្ពីរលោកុប្បត្តិ ១:៣១)។ ពិតណាស់ ការនេះបូករួមទាំងការល្អប្រសើរបំផុតភាពវិសុទ្ធរបស់ពួកទេវតា នៅពេលដែលពួកគេត្រូវបានបង្កើតឡើងនោះ។ យ៉ាងណាមិញ បទគម្ពីរបានរៀបរាប់អំពីការធ្លាក់ចុះដ៏សោកសៅរបស់ពួកគេ។ សូមយើងពិចារណាអំពីសមត្ថភាពរបស់ពួកទេវតា ទាំងក្នុងការធ្វើសកម្មភាពត្រឹមត្រូវ និង សកម្មភាពខុសឆ្គង ព្រមទាំងពិចារណាអំពីសមត្ថភាពរបស់ពួកគេនៅក្នុងការស្គាល់ និង គោរពទៅតាមក្បួនខ្នាតនៃឥរិយាបថត្រឹមត្រូវ។

## *លំហាត់អនុវត្តន៍*

៥ សូមអានខគម្ពីរយោង ហើយបំពេញប្រយោគខាងក្រោម។

ក) គម្ពីរយ៉ូហាន៨:៤៤។ អំពើបាបមួយដែលបណ្តាលឲ្យមានការធ្លាក់ចុះរបស់អារក្សគឺ

..........................................................................................................

ខ) គម្ពីរ២ពេត្រុស២:៤ ។ ព្រះជាម្ចាស់មិនយោគយល់ដល់ពួកទេវតាឡើយនៅពេលដែល

..........................................................................................................

គ) គម្ពីរយូដាស៦ ។ ទេវតាខ្លះមិនបានរក្សា..................................................របស់ពួកគេ ប៉ុន្តែពួកគេបែរជា..........................................................................................

ឃ) គម្ពីរ១ធីម៉ូថេ ៣:៦ ។ មូលហេតុសំខាន់មួយនៃការធ្លាក់ចុះរបស់អារក្សគឺអំពើបាបនៃការ

.........................................................................................................

# ពួកទេវតាបានធ្វើការជ្រើសរើស

ដូចដែលយើងបានឃើញហើយថា ទេវតាទាំងអស់ត្រូវបង្កើតមកដំបូងឲ្យមានភាពល្អឥតខ្ចោះ។ ដំបូងមេត្រីភាព ឬ សេចក្តីស្រឡាញ់របស់ពួកគេគឺត្រូវថ្វាយទៅព្រះអាទិករដែលបង្កើតពួកគេ ហើយពួកគេមានទំនោរចង់ធ្វើអ្វីទៅតាមបំណងព្រះហឫទ័យរបស់ទ្រង់។ ទោះបីជាព្រះគម្ពីរមិនបានផ្តល់សេចក្តីលំអិតមកឲ្យយើង យើងក៏ជឿថា នៅក្នុងដំណាក់កាលនេះពួកគេមានសមត្ថភាពទាំងក្នុង*ការប្រព្រឹត្តិអំពើបាប ឬ មិនប្រព្រឹត្តិពើបាប។* ច្បាស់ណាស់ ពួកគេដឹងខ្លួនច្បាស់អំពីឋានៈរបស់ពួកគេ និង អំពីទំនាក់ទំនងរបស់ពួកគេទៅនឹងអ្នកដែលបានបង្កើតពួកគេមក។ ពួកគេក៏ប្រាកដជាបានដឹងហើយ ថាការស្តាប់បង្គាប់ ឬ ការមិនស្តាប់បង្គាប់របស់ពួកគេ នឹងជាកំណត់វាសនាទៅថ្ងៃអនាគតរបស់ពួកគេ។

នៅពេលដែលពួកទេវតាមានសិទ្ធិក្នុងការជ្រើសរើស ក្នុង*ការប្រព្រឹត្តិអំ*ពីបាប ឬ មិន*ប្រព្រឹត្តិ* អំពើបាប ពួកគេក៏មិនត្រូវបាន*បង្ខិតបង្ខំ* ឲ្យស្តាប់បង្គាប់តាមព្រះជាម្ចាស់ ហើយរក្សាឋានៈរបស់ពួកគេឡើយ។ ជម្រើសរបស់ពួកគេ គឺធ្វើឡើងដោយការស្ម័គ្រចិត្តទាំងស្រុង។ ជាអកុសល ពួកគេមិនបានដឹងពីរឿងដែលកើតឡើងនៅជុំវិញសោកនាដកម្ម នៅពេលដែលមួយផ្នែកនៃពួកទេវតាធ្លាក់ចុះនោះឡើយ។ យ៉ាងណាមិញ ដោយមានការជំរុញពីព្រះជាម្ចាស់ លោកប៉ូលបានបញ្ជាក់ថា ការធ្លាក់ចុះរបស់ពួកមារ កើតមានឡើង ដោយសារអំណួតរបស់គេ (មោទនភាពជ្រុល) (គម្ពីរ១ធីម៉ូថេ ៣:៦)។

មានផ្នែកជាច្រើននៅក្នុងបទគម្ពីរ ដែលនិយាយជាអាទិ៍អំពីស្តេចរបស់លោកីយ៍ ក៏ហាក់បីដូចជានិមិត្តសញ្ញាតំណាងឲ្យសាតាំងផងដែរ។ ឧទាហរណ៍ នៅក្នុងគម្ពីរអេសេគាល ២៨:១២-១៩ បានប្រាប់ថា ស្តេចនៃក្រុងទីរ៉ុស បានធ្លាក់ចុះ ដោយសារតែមោទនភាពជ្រុលទៅលើភាពស្រស់ស្អាតរបស់ខ្លួន។ អំណួតនេះ បានបំផ្លាញសមត្ថភាពរបស់គេក្នុងការប្រព្រឹត្តិរឿងត្រឹមត្រូវ ឬ ធ្វើការវិនិច្ឆ័យត្រឹមត្រូវ។

ស្តេចស្រុកបាប៊ីឡូន ក៏ត្រូវបានដាក់ទោសឲ្យវិនាសហិនហោចដោយសារតែអំណួតជ្រុល និង មហិចតាផងដែរ បើយោងទៅតាមគម្ពីរអេសាយ ១៤: ១២-១៥។ មិនថាឧទាហណ៍ទាំងនេះនិយាយគ្រាន់តែជាតំណាងឲ្យការធ្លាក់ចុះរបស់សាតាំង ឬអត់ ក៏យើងដឹងថាមានទេវតាខ្លះ ធ្វើតាមបំណងចិត្តរបស់ពួកគេ ដោយបានជ្រើសរើសយកការចាកចេញពីតំណែងនៃសិទ្ធិអំណាច និង ផ្ទះរបស់ពួកគេ (គម្ពីរយូដាស ៦)។

ឥរិយាបថដែលបានធ្វើឲ្យអារក្សមានបាប ហាក់បីដូចជាបានចម្លងទៅលើពួកទេវតាមួយចំនួនធំដែរ។ គម្ពីរវិវរណៈ ១២:៤ ប្រហែលជាបាននិយាយអំពីហេតុការណ៍ នៅពេលដែលទេវតាមួយភាគបី បានដើរតាមសាតាំងក្នុងការប្រឆាំងទាស់ជាមួយព្រះជាម្ចាស់។ ទោះជាយ៉ាងណា យើងដឹងថាសាតាំងគឺជាមេបោកបញ្ឆោតខាងវិញ្ញាណ (គម្ពីរយ៉ូហាន ៨:៤៤) ។ ដោយសាតាំង និង ទេវតាឯទៀតដែលបានបះបោរ ដែលនេះជាជម្រើសធ្វើឡើងសម្រាប់ខ្លួនឯង និង ប្រយោជន៍ផ្ទាល់ខ្លួន មិនមែនជាជម្រើសសម្រាប់ព្រះជាម្ចាស់ និង ប្រយោជន៍របស់ទ្រង់នោះទេ។ លទ្ធផលដែលបានមកពីការនេះ គឺភាពមហន្តរាយ និង ការកាត់

ទោសដែលមកតាមក្រោយៈ "ដ្បិតព្រះជាម្ចាស់ពុំបានយោគយល់ដល់ពួកទេវតា*ដែលប្រព្រឹត្តអំពើបាប"។ (គម្ពីរ២ពេត្រុស ២:៤)។

ការសង្គ្រោះ ដែលបានកំណត់ទុកជាមុនដើម្បីបំពេញតម្រូវការខាងវិញ្ញាណរបស់មនុស្ស គឺមិនមានសម្រាប់ពួកទេវតាដែលបានធ្លាក់ចុះនោះទេ។ ទេវតាមិនវិសុទ្ធ នៅតែមានវត្តមាននៅក្នុងស្ថានរបស់ "មារកំណាច" (គម្ពីរម៉ាថាយ ៦:១៣, ១៣:៩ គម្ពីរ១យ៉ូហាន ៥:១៨-១៩)។ ការបន្តមានវត្តមានរបស់ពួកគេ ដែលយើងនឹងពិភាក្សានៅក្នុងផ្នែកបន្ទាប់ទៀត គឺជាការព្រមានដដែលសម្រាប់យើង អំពីគ្រោះថ្នាក់ដែលបានមកពីការបដិសេធព្រះជាម្ចាស់ ឬ ការធ្វេសប្រហែសចំពោះព្រះគុណដែលទ្រង់ប្រទានមកឲ្យយើង។

ទេវតាខ្លះដែលប្រព្រឹត្តិអំពើបាប ត្រូវបានវិនិច្ឆ័យទោស ហើយក៏បានក្លាយជាផ្នែកនៃទេវតារបស់មារកំណាច (គម្ពីរម៉ាថាយ ២៥:៤១) ។ ទេវតាឯទៀតដែលមិនបានប្រព្រឹត្តិបាប ពួកគេនៅជាប់ជាមួយព្រះវរបិតា និង "ទេវតាដ៏វិសុទ្ធ" របស់ទ្រង់ (គម្ពីរម៉ាកុស ៨:៣៨)។ បទគម្ពីរ មិនបានប្រាប់ច្រើនទៀតទេ អំពីការបះបោរ និង ការវិនិច្ឆ័យទោសពួកទេវតា។ ដូច្នេះ ពួកទេវតាហាក់បីមានភាពច្បាស់លាស់នៅក្នុងការសម្រេចចិត្តរបស់ពួកគេ ថាអ្នកណាជ្រើសរើសធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះវរបិតានឹងបានវិសុទ្ធជារៀងរហូត ហើយអ្នកណាជ្រើសរើសផលប្រយោជន៍របស់ខ្លួន គឺក្លាយជាអាក្រក់ជារៀងរហូត។

ពួកទេវតាដ៏វិសុទ្ធគឺជាពួកទេវតាដែលបានជ្រើសរើស ការបន្តទំនាក់ទំនងរបស់ពួកគេជាមួយព្រះជាម្ចាស់ សម្លឹងមើលទៅឯព្រះវរបិតាគង់នៅស្ថានបរមសុខ (គម្ពីរម៉ាថាយ ១៨:១០) និង ធ្វើតាមបំណងព្រះហឫទ័យរបស់ទ្រង់ (គម្ពីរម៉ាថាយ ៦:១០)។ ពួកគេត្រូវបានចាត់ទុកជាទេវតានៃពន្លឺ (ជាអ្នកដែលសាតាំងព្យាយាមក្លែងខ្លួនធ្វើតាម ឬ ធ្វើជាតំណាង - គម្ពីរ២កូរិនថូស ១១:១៤)។

## *លំហាត់អនុវត្តន៍*

៦ ចូរជ្រើសរើសថាតើប្រយោគណា ត្រូវបាន ព្រះគម្ពីរ*គាំទ្រច្បាស់ៗ* អត្ថបទ*បញ្ជាក់* ឬ ដោយភាសានិមិត្តរូប ឬ *មិនគាំទ្រដោយគម្ពីរសោះ*។

.........ក) សាតាំងធ្លាក់ចុះ ដោយសារអំណួត ឬ មោទនភាពជ្រុលលើខ្លួនឯង។

.........ខ) ទេវតាត្រូវបានបង្កើតមកឲ្យល្អឥតខ្ចោះ។

.........គ) ទេវតាមួយភាគបី បានជ្រើសរើសដើរតាមសាតាំង។

........ឃ) ទេវតាដែលបានធ្លាក់ចុះទាំងអស់នឹងមានឱកាសលន់តួបាបរបស់គេ។

........ង) ទេវតាទាំងអស់បានធ្វើការជ្រើសរើសដោយស្ម័គ្រមិនថាក្នុងការប្រព្រឹត្តិបាប និង ការមិនប្រព្រឹត្តិធ្វើបាបទេ។

.........ច) ព្រះជាម្ចាស់បានប្រកាសការវិនិច្ឆ័យភ្លាមៗចំពោះទេវតាដែលបានប្រព្រឹត្តិបាប។

១) គម្ពីរគាំទ្រច្បាស់ៗ
២) អត្ថបទបញ្ជាក់
៣) មិនគាំទ្រដោយគម្ពីរសោះ

........ឆ) ទេវតាទាំងអស់មានភាពច្បាស់នៅក្នុងការសម្រេចចិត្ត
របស់ពួកគេ មិនថាការប្រព្រឹត្តិបាប ឬ មិនប្រព្រឹត្តិបាប។

........ជ) សាតាំងត្រូវបានចាត់ទុកជាទេវតានៃពន្លឺ។

........ឈ) មានតែទេវតាដ៏វិសុទ្ធប៉ុណ្ណោះដែល ធ្វើការតាមបំណង
ព្រះហឫទ័យរបស់ព្រះជាម្ចាស់ ឯទេវតាអាក្រក់វិញ
ធ្វើការតាមបំណងរបស់សាតាំង។

........ញ) ចាប់តាំងពីត្រូវបានបង្កើតឡើងដំបូង សាតាំងគឺអាក្រក់
ទៅហើយ។

---

# គ. ចំនួនរបស់ទេវតា

**វត្ថុបំណងទី៣.** *សង្ខេបសេចក្តីបង្រៀននៅក្នុងព្រះគម្ពីរ ដែលទាក់ទងនឹងចំនួនរបស់ទេវតា។*

មុនពេលយើងចូលទៅមើលឲ្យកាន់តែស៊ីជម្រៅអំពីការរៀបចំ និង សកម្មភាពរបស់ទេវតាដ៏វិសុទ្ធ និងទេវតាមិនវិសុទ្ធ ចូរយើងក្រឡេកទៅមើលពីអ្វីដែលព្រះគម្ពីរចែងពីចំនួនរបស់ទេវតាជាមុនសិន។ នៅពេលដែល បទគម្ពីរមិនបានប្រាប់ពីចំនួនជាក់លាក់របស់ពួកទេវតា យើងនៅតែដឹងថាពួកគេមានបរិមាណ និង ចំនួនច្រើនសន្ធឹកសន្ធាប់។ យើងរកឃើញបទគម្ពីរទាំងប៉ុន្មានខាងក្រោមនេះ អំពីចំនួនយ៉ាងច្រើនសន្ធឹករបស់ពួកទេវតា៖

១. នៅពេលដែលលោកហោរាអេលីសេ និង អ្នកបម្រើរបស់លោកត្រូវបានលោមព័ន្ធនៅក្នុងក្រុងដូថាន់ ដោយកងទ័ពស៊ីរីដ៏មានអំណាចខ្លាំងក្លា ព្រះជាម្ចាស់បានចាត់បញ្ជូនទ័ពទេវតាដ៏ធំជាងនេះទៅទៀត មកដើម្បីការពារអ្នកបម្រើរបស់លោក។(គម្ពីរ១ពង្សាវតារក្សត្រ ៦:១៤-១៧)

២. ដោយយោងទៅតាមអ្នកនិពន្ធទំនុកតម្កើង "ទ័ពសេះរបស់ព្រះជាម្ចាស់ មានចំនួនរាប់លានរាប់កោដិ ព្រះអង្គគង់ជាមួយពួកគេនៅភ្នំស៊ីណៃជាទីសក្ការៈរបស់ព្រះអង្គ។" (គម្ពីរទំនុកតម្កើង ៦៨:១៧)

៣. នៅក្នុងការឲ្យពរទៅជនជាតិអ៊ីស្រាអែលលោកម៉ូសេបាននិយាយអំពីព្រះអម្ចាស់ដែលបានយាងមកជាមួយនឹង "ទេវតា*យ៉ាងច្រើនអនេកអនន្ត (ច្រើនមិនអាចរាប់បាន)" (គម្ពីរទុតិយកថា ៣៣:២)

៤. នៅក្នុងបទទំនាយទុកជាមុន លោកដានីយ៉ែលបានឃើញព្រះជាម្ចាស់នៃពេលវេលាដែលមានព្រះជន្មាយុឃឺនយូរ គង់នៅលើបល្ល័ង្ក នៃការវិនិច្ឆ័យ។ លោកដានីយ៉ែលរៀបរាប់អំពីព្រឹត្តិការណ៍នោះថា ៖ "មានមនុស្សរាប់ម៉ឺនរាប់សែននាក់គោរពបំរើព្រះអង្គ និងរាប់លានរាប់កោដិនាក់ទៀតឈរនៅចំពោះព្រះភក្ត្រព្រះអង្គ។" (គម្ពីរដានីយ៉ែល ៧:១០)។

៥. អ្នកនិពន្ធគម្ពីរហេប្រឺបានក្រើនរំឭកអ្នកអានរបស់លោកអំពីអភ័យឯកសិទ្ធិដ៏រុងរឿង នៃការចូលទៅឯព្រះជាម្ចាស់ដ៏មានព្រះជន្មរស់ ដែលនៅក្នុងព្រះវត្តមានរបស់ទ្រង់មានការប្រមូលផ្តុំដ៏ពេញដោយអំណរនៃ "ទេវតា*រាប់លានរាប់កោដិ" (គម្ពីរហេប្រឺ ១២:២២)

៦. ចុងក្រោយ នៅពេលដែលព្រះជាម្ចាស់បានប្រទានឲ្យលោកយ៉ូហានដែលជាសាវ័កសំណព្វ បានឃើញពីទិដ្ឋភាពដ៏ពេញដោយព្រះចេស្តានៃទីកាត់ក្តីនៅស្ថានបរមសុខរបស់ទ្រង់ លោកយ៉ូហាន

ថាសរសេរថាៈ "ពេលនោះ ខ្ញុំមើលទៅ ហើយឮសូរសំឡេងទេវតា*យ៉ាងច្រើននៅជុំវិញបល្ល័ង្ក ជុំវិញសត្វមានជីវិត និងជុំវិញពួកព្រឹទ្ធាចារ្យ។ ទេវតាទាំងនោះមានចំនួនរាប់ម៉ឺនរាប់សែន ច្រើនអនេកអនន្ត" (គម្ពីរវិវរណៈ ៥:១១)

តាមភស្តុតាងនេះ យើងឃើញថាចំនួនទ័ពទេវតា ឬ ទេវតាដ៏វិសុទ្ធ គឺពិតជាច្រើនណាស់។ លើសពីនេះទៅទៀត យើងដឹងថាកងទ័ពទេវតាកំណាចរបស់សាតាំង ក៏មានវត្តមាន ហើយដឹងថាចំនួនរបស់ពួកគេក៏ច្រើនសន្ធឹកដែរ (គម្ពីរវិវរណៈ ១២:៧-១២)។

## *លំហាត់អនុវត្តន៍*

៧ ព្រះគម្ពីរបង្រៀនអ្វីអំពីចំនួនពួកទេវតា?

ក) មានទេវតាធ្លាក់ចុះច្រើនជាងទេវតាដែលនៅស្មោះត្រង់ជាមួយព្រះជាម្ចាស់។

ខ) មានទេវតាជាច្រើនរាប់មិនអស់ ទាំងល្អនិងអាក្រក់ ។

គ) ទេវតាច្រើននៅបម្រើព្រះជាម្ចាស់ ហើយមានទេវតាមួយចំនួនតូចទៅបម្រើសាតាំង។

ឃ) ចំនួនទេវតា កំពុងថយចុះ។

# ឃ. ការរៀបចំនិងសកម្មភាពរបស់ពួកទេវតា

## ភស្តុតាងអំពីការរៀបចំ

**វត្ថុបំណងទី៤.** *បង្ហាញភស្តុតាងនៃសកម្មភាពដែលបានរៀបចំរបស់ពួកទេវតាដ៏វិសុទ្ធ។*

មានភស្តុតាងក្នុងបទគម្ពីរជាច្រើនដែល បង្ហាញពីការរៀបចំកម្លាំងដែលមានប្រសិទ្ធិភាពខាងឯវិញ្ញាណ ដើម្បីធ្វើកិច្ចការដែលបានប្រទានឲ្យពួកគេ។ បទគម្ពីរខ្លះនៅក្នុងបទគម្ពីរទាំងនេះ គឺមានដូចខាងក្រោមៈ

១. គម្ពីរ១ពង្សាវតារក្សត្រ២២:១៩ ។ លោកព្យាការីមីកាបង្ហាញអ្វីម្យ៉ាងអំពីការរៀបចំរបស់ពួកទេវតាៈ "ទូលបង្គំបានឃើញព្រះអម្ចាស់គង់លើរាជបល្ល័ង្ក ហើយមានកងពលនៃស្ថានបរមសុខទាំងមូលឈរគាល់ព្រះអង្គ ទាំងឆ្វេង ទាំងស្តាំផង។" ព្រះជាម្ចាស់គង់នៅលើរាជបល្ល័ង្ក កងពល (ពួកទេវតា) នៃស្ថានបរមសុខទាំងមូល នៅជុំវិញទ្រង់។

២. គម្ពីរម៉ាថាយ ២៦:៥៣។ព្រះយេស៊ូបានមានព្រះបន្ទូលទាំងនេះទៅកាន់លោកពេត្រុសៈ "អ្នកស្មានថា ខ្ញុំមិនអាចអង្វរករព្រះបិតាខ្ញុំអោយចាត់ទេវតាជាងដប់ពីរកងពល មកជួយខ្ញុំបានភ្លាមៗទេឬ?" នេះបង្ហាញឲ្យឃើញអំពីអ្វីដែលស្រដៀងនៅនឹងការរៀបចំកងទ័ពរ៉ូម៉ាំងដែរ។ ព្រះបន្ទូលត្រង់នេះក៏ប្រាប់ថា ពួកទេវតាតែងតែប្រុងប្រៀប និងត្រៀមខ្លួនដើម្បីធ្វើតាមការបញ្ជារបស់ព្រះវរបិតានៃស្ថានបរមសុខ។

៣. គម្ពីរលូកា ២:៨-១៤ ។ ទេវតានាំសារដែលបានលេចមកឯអ្នកគង្វាល ហើយបានធ្វើការប្រកាសអំពីកំណើតរបស់ព្រះយេស៊ូ ក៏ត្រូវបានចូលរួមដោយ "ទេវតាច្រើនកុះករ ចុះពីស្ថានបរមសុខ" ។ ទេវតានាំសារ និង ក្រុមទេវតាខាងចម្រៀងបានបន្លឺសម្លេងចម្រៀងនៃការសរសើរតម្កើងថ្វាយទៅដល់

ព្រះជាម្ចាស់។ ទេវតាដែលមានលក្ខណៈបុគ្គល និង ក្រុមទេវតាខាងចម្រៀង ច្បាស់ជាបានឆ្លើយតបទៅតាមបំណងព្រះហឫទ័យរបស់ព្រះវរបិតា និង ធ្វើការទៅតាមការងាររៀងៗខ្លួន។

៤. គម្ពីរវិវរណៈ ១៩:១០-១៤ ។ និមិត្តរបស់លោកយ៉ូហាន អំពីកងទ័ពទេវតាដែលមានជោគជ័យ នៅក្នុងពេលនៃការយាងមកដល់របស់ព្រះអម្ចាស់ ក៏បានបង្ហាញពី ភាពសុក្រឹត សណ្ដាប់ធ្នាប់ ការរៀបចំ សិទ្ធិអំណាច និង គោលបំណងផងដែរ៖ "កងទ័ពនៅស្ថានសួគ៌នាំគ្នាជិះសេះ ស មកតាមព្រះអង្គ ទាំងស្លៀកពាក់សំពត់ទេសឯកពណ៌ស និងបរិសុទ្ធ*។" អ្នកប្រហែលជាបានសំគាល់ឃើញថា បទគម្ពីរបានថែងពីការរៀបចំរបស់ពួកទេវតា។ នៅក្នុងផ្នែកក្រោយៗទៀតនៃមេរៀននេះ យើងនឹងឃើញថា កម្លាំងនៃសេចក្ដីអាក្រក់ ក៏ត្រូវមានការរៀបចំដែរ។ ជាពិសេស ពួកគេត្រូវបានរៀបចំ ដើម្បីទាស់ប្រឆាំងជាមួយព្រះជាម្ចាស់។

## សកម្មភាពដែលមានការរៀបចំរបស់ទេវតាដ៏វិសុទ្ធ

ដោយសារយើង ត្រូវប្រឈមមុខជាមួយនឹងទេវតាពីរក្រុមដោយឡែកគ្នា មានទេវតាវិសុទ្ធ និង ទេវតាមិនវិសុទ្ធ ឬ ទេវតាអាក្រក់ យើងត្រូវពិនិត្យមើលកិច្ចការដែលទេវតាដ៏វិសុទ្ធធ្វើជាមុនសិន។ នៅពេលដែលយើងស្វែងយល់ពីកិច្ចការដែលពួកគេធ្វើហើយ យើងត្រូវយល់បន្ថែមទៀតអំពីរបៀបដែលពួកគេរៀបចំដើម្បីធ្វើកិច្ចការនេះ។

*ពួកទេវតាថ្វាយបង្គំព្រះជាម្ចាស់។* នៅក្នុងចំណោមរូបភាពទាំងប៉ុន្មាននៃទេវតាដ៏វិសុទ្ធដែលត្រូវបានបង្ហាញនៅក្នុងបទគម្ពីរ ក៏មានរូបភាពស្ដីពីពួកទេវតាដែលកំពុងឈរនៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់ និងកំពុងតែថ្វាយបង្គំទ្រង់ផង (គម្ពីរទំនុកតម្កើង ១០៣:២០; ១៤៨:២ គម្ពីរអេសាយ ៦:១-៧) ។ ពួកគេលើកសម្លេងរបស់ពួកគេឡើង ច្រៀងជាចម្រៀងនៃការសរសើរដ៏មានចេស្ដា ដ្បិតទ្រង់ស័ក្ដិសមទទួលការសរសើរពីស្នាព្រះហស្ដរបស់ទ្រង់។ ពួកគេថ្វាយបង្គំព្រះជាម្ចាស់ ដោយទ្រង់គឺជាព្រះ និង សម្រាប់អ្វីដែលទ្រង់បានប្រទាន និងសម្រាប់អ្វីដែលទ្រង់បានប្រើប្រាស់ដើម្បីសម្រេចបាននូវការប្រោសលោះ (ប្រៀបធៀបទៅគម្ពីរវិវរណៈ៥:៩-១២ជាមួយ៥:១៣-១៤)។

ពួកទេវតាដ៏វិសុទ្ធ សាទរនឹងកិច្ចការនៃការបង្កើតរបស់ព្រះជាម្ចាស់ នៅក្នុងធម្មជាតិ (គម្ពីរយ៉ូប ៣៨:៧) និង ចំពោះការអស្ចារ្យដ៏ស្រស់បំព្រងដែលទ្រងធ្វើ ដើម្បីផ្លាស់ប្រែមនុស្សបាប និង នាំពួកគេឲ្យចូលមកក្នុងគ្រួសាររបស់ទ្រង់ (គម្ពីរលូកា ១៥:១០)។ ស្ថានសួគ៌ត្រូវបានបើកចំហ ជាព្រះវិហារដ៏រុងរឿងមួយ ដែលមានពួកទេវតាលេចមក ជា*ក្រុមជំនុំនៃស្ថានបរមសុខ* ។ នៅក្នុងព្រះវិហារនោះ ពួកគេថ្វាយបង្គំ និងសរសើរតម្កើងព្រះជាម្ចាស់ ដែលពួកគេស្ថិតនៅក្នុងព្រះវត្តមានរបស់ទ្រង់គ្រប់ពេល។ (គម្ពីរម៉ាថាយ ១៨:១០)។

*ទេវតា គឺជាវិញ្ញាណដែលចាំដឹកនាំបម្រើ ។* ទេវតាមិនត្រឹមតែថ្វាយបង្គំ ព្រះជាម្ចាស់ និង សាទរនៅក្នុងព្រះវត្តមានរបស់ទ្រង់ និង កិច្ចការរបស់ទ្រង់នោះទេ ពួកគេក៏ធ្វើកិច្ចការទៅតាមបំណងព្រះហឫទ័យរបស់ទ្រង់ផងដែរ (គម្ពីរទំនុកដំកើង១០៣:២០) ។ ក្នុងនាមជាទេវតាដឹកនាំបម្រើ ពួកទេវតាត្រូវបានចាត់បញ្ជូនមកដើម្បីបម្រើអស់អ្នកដែលនឹងទទួលមរតកនៃការសង្គ្រោះ (គម្ពីរហេប្រឺ ១:១៤) ។ ចូរសំគាល់

មើលពីរបៀបដែលព្រះជាម្ចាស់ប្រទានការបម្រើរបស់ពួកទេវតានេះ ទាំងនៅក្នុងសម័យសម្ព័ន្ធមេត្រីចាស់ និង សម្ព័ន្ធថ្មី៖

១. លោកប៉ូលកាលនៅជាអ្នកទោសម្នាក់ ដែលកំពុងស្ថិតនៅក្នុងកាលៈទេសៈដ៏គ្រោះថ្នាក់មួយ បានទទួល*ការលើកទឹកចិត្តពីទេវតា* (គម្ពីរកិច្ចការ ២៧:២៣-២៤)។

២. លោកភីលីព*ទទួលបានការដឹកនាំនៅក្នុងព័ន្ធកិច្ច* ពីទេវតា (គម្ពីរកិច្ចការ ៨:២៦) ។

៣. លោកកូនេលាស ទទួលបាន*ជំនួយ* ពីទេវតា នៅក្នុងការស្វែងរកភាពស្គប់ស្គាល់នៅក្នុងព្រះជាម្ចាស់បន្ថែមទៀត (គម្ពីរកិច្ចការ ១០:៣-៧)។

៤. លោកពេត្រុស ត្រូវបាន*រំដោះ* ដោយទេវតាយ៉ាងអស្ចារ្យ (គម្ពីរកិច្ចការ ១២:៧-១០)។

៥. នៅក្នុងព្រឹត្តិការណ៍ដែលត្រូវបានកត់ត្រាទុក ព្រះយេស៊ូបាន*ទទួលកម្លាំងបន្ថែម* ដោយពួកទេវតា (គម្ពីរម៉ាថាយ ៤:១១ លូកា ២២:៤៣)។

៦. លោកអេលីសេ *ត្រូវបានការពារ* ផុតពីកងទ័ពសាសន៍ស៊ីរី ដោយទេវតាដ៏វិសុទ្ធមួយក្រុម (គម្ពីរ ២ពង្សាវតារក្សត្រ ៦:៨-២៣)។

៧. លោកដាវីឌ ត្រូវបានគេទទួលស្គាល់ បន្ទាប់ពីការភៀសខ្លួនរបស់លោក ពីស្តេចអប៊ីម៉ាឡេក (គម្ពីរ១សាំយូអែល ២១:១០-២២:១) ដែលពេលនោះលោកបានទទួល*ការការពារ និង រំដោះ* ដោយពួកទេវតា (សូមមើលគម្ពីរ ទំនុកតម្កើង ៣៤:៧)។

*ពួកទេវតាគឺជាភ្នាក់ងារនៃការវិនិច្ឆ័យទោស*។ នៅក្នុងការធ្វើកិច្ចការតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ពួកទេវតាក៏ជាភ្នាក់ងារនៅក្នុងការវិនិច្ឆ័យទោស ការដាក់ទោសសត្រូវរបស់ព្រះជាម្ចាស់ផងដែរ។ ឧទាហរណ៍មួយនៃការនេះ គឺឃើញមាននៅក្នុងគម្ពីរ២ពង្សាវតារក្សត្រ ១៩:៣៥៖ " នៅយប់នោះទេវតា*របស់ព្រះអម្ចាស់បានចេញមកវាយទីតាំងទ័ពរបស់ពួកអាស្ស៊ីរី ហើយប្រហារជីវិតពួកគេអស់មួយសែនប្រាំបីម៉ឺនប្រាំពាន់នាក់" ។ នៅក្នុងគម្ពីរកិច្ចការ១២:២៣ ក៏មានចែងថា៖ "រំពេចនោះ ស្រាប់ តែមានទេវតារបស់ព្រះជាម្ចាស់មកប្រហារស្តេចហេរ៉ូដ ព្រោះទ្រង់ពុំបានថ្វាយសិរីរុងរឿងទៅព្រះជាម្ចាស់។ ស្តេចត្រូវដង្កូវចោះ ហើយក៏ផុតដង្ហើមទៅ។"

មានបទគម្ពីរជាច្រើនទៀត ដែលនិយាយអំពីកិច្ចការរបស់ពួកទេវតា ជាភ្នាក់ងារដែលធ្វើការតាមគម្រោងការរបស់ព្រះជាម្ចាស់ ជាភ្នាក់ងារក្នុងការវិនិច្ឆ័យទោសរបស់ទ្រង់ ទាំងនៅអតីតកាល និង នៅអនាគត ហើយក៏ជាកម្លាំងពិសេសដែលរួមដំណើរជាមួយព្រះអម្ចាស់ នៅក្នុងពេលដែលទ្រង់យាងត្រឡប់មកវិញផងដែរ។

## *លំហាត់អនុវត្តន៍*

៨ តើទេវតាដ៏វិសុទ្ធមានចូលរួមនៅក្នុងសកម្មភាពណាខ្លះ នៅខាងក្រោមនេះ ? ពួកលោក

ក) ថ្វាយបង្គំ និង សរសើរតម្កើងព្រះជាម្ចាស់ ហើយធ្វើតាមបំណងព្រះហឫទ័យរបស់ទ្រង់។

ខ) បម្រើអ្នកដែលត្រូវប្រោសលោះ នៅលើផែនដី ក្នុងនាមជាវិញ្ញាណដែលបម្រើ។

គ) ថ្កោលទោសមនុស្សបាប ហើយនាំពួកគេឲ្យលន់តួ។

ឃ) ការពារ រំដោះ ដឹកនាំ លើកទឹកចិត្ត និង ផ្តល់កម្លាំងឲ្យមនុស្សរបស់ព្រះជាម្ចាស់។

ង) ដើរតួជាភ្នាក់ងារនៃការវិនិច្ឆ័យទោស និងការដាក់ទោសសត្រូវរបស់ព្រះជាម្ចាស់។

---

*ទេវតាហាក់បីដូចជាមានឥទ្ធិពល នៅក្នុងកិច្ចការរបស់ប្រទេសជាតិផងដែរ*។ គម្ពីរដានីយ៉ែល ១០:១៣,២០ បង្ហាញថាមានក្សត្រអាក្រក់នៅក្នុងប្រជាជាតិជាច្រើន ហើយពួកគេត្រូវបានរារាំងដោយទេវតាដ៏វិសុទ្ធ។ តាមខគម្ពីរយោងនេះ និង គម្ពីរដានីយ៉ែល ១០:២១-១១:១ យើងសន្និដ្ឋានបានថា ពួកទេវតា ពិតជាត្រូវបានចាត់ឲ្យទទួលខុសត្រូវ កិច្ចការរបស់ប្រទេសជាតិមែន ។ តាមរយៈការប្រៀបធៀបខគម្ពីរយោងទាំងនេះនៅក្នុងគម្ពីរដានីយ៉ែល ជាមួយនឹងគម្ពីរអេភេសូ ១:២១; ៦:១២ និង គម្ពីរកូឡុស ១:១៦; ២:១៥ យើងឃើញថាសង្គ្រាមខាងវិញ្ញាណ កំពុងកើតឡើងគ្រប់ពេលវេលានៅឯស្ថានបរមសុខ។ សង្គ្រាមនេះស្តែងឡើងដោយ កម្លាំងនៃវិញ្ញាណអាក្រក់ បញ្ឆោតគំនិត និង សុច្ឆន្ទៈ របស់មនុស្សប្រុសស្រី ហើយជាលទ្ធផល ព្រលឹងរបស់គេទាំងមូលក៏ត្រូវបានបោកបញ្ឆោត។

នៅពេលខ្លះ សង្គ្រាមនេះហាក់បីដូចជាមានស្មិតស្មាញ ខ្លាំងណាស់ ដែលសូម្បីតែ*មហាទេវតា* ក៏បានចូលរួមច្បាំងដោយផ្ទាល់ផងដែរ។ *ទេវតាមីកែល* ដែលត្រូវបានគេហៅថា មហាទេវតា នៅក្នុងគម្ពីរយូដាស ៩ គឺជា*អ្នកដឹកនាំ* ទ័ពទេវតាដ៏វិសុទ្ធ។ លោកក៏ត្រូវបានគេហៅថា ក្សត្រានៃប្រជាជាតិអ៊ីស្រាអែល ហើយកិច្ចការរបស់លោកគឺបូករួមទាំងការការពារ និង ធ្វើឲ្យប្រជាជាតិនេះបានរីកចម្រើន (គម្ពីរដានីយ៉ែល ១០:១៣, ២១; ១២:១)។ លោកនឹងលើកសម្លេងរបស់លោកឡើងដោយការសរសើរតម្កើង នៅពេលព្រឹត្តិការណ៍នៃការយាងត្រឡប់មកវិញរបស់ព្រះអម្ចាស់ ចាប់ផ្តើម (គម្ពីរ១ថែស្សាឡូនិក ៤:១៦)។

មានតែទេវតាពីរអង្គតែប៉ុណ្ណោះ ដែលត្រូវបានលើកយកមកនិយាយចំឈ្មោះនៅក្នុងបទគម្ពីរ៖ ទេវតាមីកែល ជាមហាទេវតា និង ទេវតាកាព្រីយ៉ែលដែលត្រូវបានបង្ហាញថាជាអ្នកនាំសារពិសេស (គម្ពីរដានីយ៉ែល ៨:១៦; ៩:២១ គម្ពីរលូកា១:១៩,២៦)។ មានទេវតានាំសារដែលមិនបានរៀបរាប់ឈ្មោះជាច្រើនអង្គផ្សេងទៀត ក៏បានបម្រើព្រះអម្ចាស់ដែលមានសមត្ថភាពដូចនេះដែរ។

ព្រះគម្ពីរបានប្រទានភស្តុតាងតែបន្តិចបន្តួចប៉ុណ្ណោះ ទាក់ទងនឹងឋានៈផ្សេងទៀតរបស់ពួកទេវតាដ៏វិសុទ្ធ៖

១. ចេរូប៊ីន (គម្ពីរលោកុប្បត្តិ ៣:២៤ គម្ពីរ២ពង្សាវតារក្សត្រ ១៩:១៥ គម្ពីរអេសេគាល ១០:១-២២; ២៨:១៤-១៦) ។ ចេរូប៊ីន គឺជាអ្នកថែរក្សារាជបល្ល័ង្ករបស់ព្រះជាម្ចាស់។ ពួកគេក៏បានយាមឃ្លោងទ្វារចូលទៅក្នុងសួនច្បារអេដែនផងដែរ។

២. សេរភីម (គម្ពីរអេសាយ ៦:២,៦) ។ សេរភីមប្រហែលជាអ្នកដឹកនាំនៅក្នុងការថ្វាយបង្គំព្រះជាម្ចាស់។ កិច្ចការចម្បងរបស់ពួកគេ គឺភាពវិសុទ្ធ និង ការបន្សុទ្ធ របស់ពួកអ្នកដែលបានប្រោសលោះ សម្រាប់ការថ្វាយបង្គំ និង ការបម្រើ ដ៏សមគួរមួយ។

៣. ពួកពិនិត្យត្រួតមើល [ពគប១៩៥៤] (គម្ពីរដានីយ៉ែល ៤:១៣,១៧) ។ ពិតណាស់ ពួកគេត្រូវបានចាត់ឲ្យឃ្លាំមើលសកម្មភាពជាក់លាក់ណាមួយ។ ពួកគេស្មោះត្រង់ជាមួយភារកិច្ចរបស់ពួកគេ ហើយដូចដែលបានឃើញនៅក្នុងអត្ថបទគម្ពីរនេះ ពួកគេក៏នាំសាររបស់ព្រះជាម្ចាស់ទៅកាន់មនុស្សជាតិផងដែរ។

៤. សត្វមានជីវិត (គម្ពីរវិវរណៈ ៤:៦-៩; ៦:១-៧; ១៥:៧)។ សត្វទេពទាំងនេះ ដូចជាមានភាពខុសគ្នានឹងសេរភីម ចេរូប៊ីន និង ទេវតាធម្មតាផ្សេងទៀត។ ពួកគេហាក់ដូចជាថ្វាយបង្គំព្រះជាម្ចាស់ រៀបចំការវិនិច្ឆ័យរបស់ទ្រង់ និង មានសកម្មភាពចំពោះរាជបល្ល័ង្ករបស់ព្រះជាម្ចាស់។

សរុបមក ពពួកទេវតាដ៏វិសុទ្ធទាំងអស់នេះ បម្រើព្រះជាម្ចាស់យ៉ាងមានប្រសិទ្ធិភាព ហើយត្រៀមខ្លួនរួចរាល់ជានិច្ចដើម្បីបំពេញកិច្ចការតាមបំណងព្រះហឫទ័យរបស់ទ្រង់សម្រាប់ប្រជារាស្ត្ររបស់ទ្រង់។

## លំហាត់អនុវត្តន៍

៩ ចូរផ្គូផ្គងឈ្មោះ ឬ ចំណែកថ្នាក់ (ខាងស្ដាំ) ទៅជាមួយនឹងការរៀបរាប់ដែលត្រឹមត្រូវ (ខាងឆ្វេង)។

| | | | |
|---|---|---|---|
| ........ក) | ពួកពិនិត្យត្រួតមើលដែល ត្រូវបានចាត់ឲ្យឃ្លាំមើលសកម្មភាពអ្វីមួយ។ | ១) | មីកែល |
| | | ២) | កាព្រីយ៉ែល |
| ........ខ) | ទេវតានាំសារពិសេសមួយរូប។ | ៣) | ពួកទេវតាដ៏វិសុទ្ធ |
| ........គ) | ទេវតាដែលការពាររាជបល្ល័ង្ករបស់ព្រះជាម្ចាស់ | ៤) | ចេរូប៊ីន |
| ........ឃ) | អ្នកដែលមមាញឹកអំពីរាជបល្ល័ង្ករបស់ព្រះជាម្ចាស់ ហើយជាអ្នកដឹកនាំការវិនិច្ឆ័យខ្លះៗ។ | ៥) | សេរភីម |
| | | ៦) | ពួកពិនិត្យត្រួតមើល |
| ........ង) | ក្រុមទេវតាទូទៅដែលចាំលើកព្រះភ័ក្ត្ររបស់ព្រះជាម្ចាស់ ថ្វាយបង្គំទ្រង់ និង ឈរប្រុងប្រៀបធ្វើតាមព្រះរាជបញ្ជារបស់ទ្រង់។ | ៧) | សត្វមានជីវិត |
| .........ច) | ពួកទេវតាដែលទាក់ទងជាពិសេសទៅនឹងភាពវិសុទ្ធនៅក្នុងព្រះវត្តមានរបស់ព្រះជាម្ចាស់ និង ការថ្វាយបង្គំដ៏សមស្រប។ | | |
| ........ឆ) | ក្សត្រាដ៏ពិសេសរបស់សាសន៍អ៊ីស្រាអែល។ | | |

# ទំហំនៃសកម្មភាពរបស់ទេវតាដ៏វិសុទ្ធ

មុនពេលបញ្ចប់មេរៀននៃសកម្មភាពរបស់ពួកទេវតាដ៏វិសុទ្ធ យើងគប្បីនិយាយអំពីសេចក្តីសន្និដ្ឋានជាច្រើនដែលយើងបានដាក់ចេញពីបទគម្ពីរ ទាក់ទងនឹង*ទំហំ* ឬ *វិសាលភាព*នៃសកម្មភាពរបស់ពួកលោក។

ទីមួយ ទេវតាដ៏វិសុទ្ធគឺជាអ្នកបម្រើនៃឧបការគុណពិសេសរបស់ព្រះជាម្ចាស់ នៅក្នុងកិច្ចការមនុស្ស និង ក្រុមជំនុំរបស់ទ្រង់ ។ គម្ពីរហេប្រឺ១:៧ ថ្លែងថា៖ "ព្រះអង្គបានយកពួកទេវតាធ្វើជាខ្យល់និងយកពួកអ្នកបំរើរបស់ព្រះអង្គធ្វើជាអណ្តាតភ្លើង" (សូមមើលផងដែរនៅក្នុងគម្ពីរទំនុកតម្កើង១០៤:៤)។ យើងអាចនិយាយបានថា ព្រះជាម្ចាស់ប្រើប្រាស់ទេវតា ជាអ្នកនាំសាររបស់ទ្រង់ មិនមែននៅក្នុងកិច្ចការធម្មតារបស់ទ្រង់នោះទេ ប៉ុន្តែនៅក្នុងការបង្ហាញជាពិសេសនៃឫទ្ធានុភាពដែលទាក់ទងទៅនឹងច្បាប់របស់ទ្រង់ (គម្ពីរទុតិយកថា ៣៣:២ គម្ពីរកិច្ចការ ៧:៥៣ គម្ពីរកាឡាទី ៣:១៩ និងគម្ពីរហេប្រឺ២:២)។ ការអន្តរាគមន៍ ឬការចូលរួមពាក់ព័ន្ធ របស់ពួកទេវតានៅក្នុងដំណើរធម្មតានៃកិច្ចការរបស់មនុស្ស ហាក់បីដូចជា កើតមានឡើងទៅតាមពេលវេលា ហើយពិសេសខុសធម្មតាទៀតផង។ ពួកទេវតាមិនធ្វើអន្តរាគមន៍ទៅតាមការសម្រេចចិត្តរបស់ពួកគេឡើយ ប៉ុន្តែគេធ្វើតាមតែការបញ្ជារបស់ព្រះជាម្ចាស់ប៉ុណ្ណោះ។ ពួកគេមិនចូលមកចន្លោះកណ្តាលរវាងព្រះជាម្ចាស់នឹងប្រជារាស្ត្ររបស់ទ្រង់នោះ។

ទីពីរ ឫទ្ធានុភាពរបស់ពួកទេវតា ដែលផ្អែកទៅលើព្រះជាម្ចាស់ និង បានមកពីទ្រង់ផងនោះ ហាក់បីដូចជាត្រូវបានដាក់ឲ្យប្រើប្រាស់ដោយយោងទៅតាមច្បាប់ខាងវិញ្ញាណផង និង ខាងឯធម្មជាតិផង។ ខុសគ្នាពីព្រះជាម្ចាស់ ទេវតាមិនអាចបង្កើត ឬធ្វើសកម្មភាពដោយគ្មានការអនុញ្ញាតរបស់ព្រះជាម្ចាស់បាន ពួកគេមិនអាចស្ទង់ជម្រៅចិត្ត ឬ ផ្លាស់ប្តូរច្បាស់ធម្មជាតិបាននោះទេ។ ពួកគេមិនអាចមានឥទ្ធិពលមកលើគំនិតរបស់មនុស្សបាននោះទេ ដ្បិតការងារនេះជាការងាររបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ ទេវតា ធ្វើការយ៉ាងជាក់ច្បាស់ ដែលស្ថិតនៅក្នុងដែនកំណត់។

ទីបី បទគម្ពីរបង្ហាញថា ជាទូទៅ ការបានបង្ហាញខ្លួនរបស់ពួកទេវតាគឺកើតឡើងនៅមុនពេល និងនាំមកជាមួយគ្នានូវចំណុចផ្លាស់ប្តូរយ៉ាងសំខាន់ថ្មីមួយនៅក្នុងផែនការរបស់ព្រះជាម្ចាស់ដែលកំពុងតែបើកសំដែង។ ឧទាហរណ៍ យើងឃើញសកម្មភាពរបស់ពួកទេវតានៅក្នុងពេលមួយនៃព្រឹត្តិការណ៍ទាំងនេះ។

- ការបង្កើតពិភពលោក (គម្ពីរយ៉ូប ៣៨:៧)
- នៅពេលផ្តល់ក្រឹត្យវិន័យ(គម្ពីរកាឡាទី ៣:១៩)
- នៅមុនពេល និងនៅក្នុងពេលព្រះគ្រិស្តប្រសូត (គម្ពីរលូកា១:១១, ២៦;២:១៣)
- នៅក្នុងអំឡុងពេល ព្រះយេស៊ូត្រូវបានល្បួងនៅក្នុងវាលរហោស្ថាន និង នៅក្នុងសួនកេតសេម៉ានី។ (គម្ពីរម៉ាថាយ ៤:១១ ឬគម្ពីរលូកា២២:៤៣)
- នៅក្នុងពេលប្រោសឲ្យព្រះយេស៊ូមានព្រះជន្មរស់ឡើងវិញ (គម្ពីរម៉ាថាយ ២៨:២)
- នៅពេលព្រះយេស៊ូយាងត្រឡប់ទៅឯនគរស្ថានសួគ៌វិញ (គម្ពីរកិច្ចការ ១:១០-១១)

- នៅក្នុងអំឡុងពេលកិច្ចការនៃគ្រាចុងក្រោយ មុនពេលដែលព្រះគ្រិស្តយាងត្រឡប់មកជាលើកទីពីរ (សូមមើលខគម្ពីរយោងជាច្រើន អំពីសកម្មភាពឬ កិច្ចការរបស់ទេវតានៅក្នុងកណ្ឌគម្ពីរវិវរណៈ និង គម្ពីរម៉ាថាយ ២៥:៣១)។

## *លំហាត់អនុវត្តន៍*

១០ ចូរគូសរង្វង់ជុំវិញអក្សរដែលនៅខាងក្នុងឃ្លាបំពេញត្រឹមត្រូវ ដែលរៀបរាប់អំពីសកម្មភាពរបស់ពួកទេវតាដ៏វិសុទ្ធ។ ពួកគេ...

ក) ធ្វើអន្តរាគមរវាងព្រះជាម្ចាស់ និង ប្រជារាស្ត្ររបស់ទ្រង់។

ខ) គឺជាអ្នកបម្រើពិសេសនៅក្នុងឧបការគុណរបស់ព្រះជាម្ចាស់។

គ) បានបង្ហាញពីឫទ្ធានុភាពដ៏អស្ចារ្យ នៅពេលផ្តល់ក្រឹត្យវិន័យ។

ឃ) មានវត្តមាននៅពេលព្រះជាម្ចាស់បង្កើតពិភពលោក។

ង) ឧបករណ៍នៅក្នុងការជះឥទ្ធិពលទៅលើគំនិតរបស់មនុស្សម្នាក់។

ច) ទទួលខុសត្រូវនៅក្នុងការល្បួងមនុស្សដោយផ្ទាល់។

ឆ) ចូលរួមជាពិសេសនៅក្នុងការការផ្លាស់ប្តូរដ៏សំខាន់នៅក្នុងផែនការនៃការសង្គ្រោះរបស់ព្រះជាម្ចាស់។

ជ) គ្រប់គ្រងលើក្រឹត្យវិន័យនៅក្នុងស្ថានវិញ្ញាណ និង នៅក្នុងធម្មជាតិ។

## សកម្មភាពដែលមានការរៀបចំរបស់ទេវតាមិនវិសុទ្ធ

**វត្ថុបំណងទី៥.** *រៀបរាប់អំពីសកម្មភាព និង វាសនាពួកទេវតាមិនវិសុទ្ធ និង អ្នកដឹកនាំរបស់ពួកគេ។*

ដូចដែលបានបង្កញថា ព្រះជាម្ចាស់មានរាជបល្ល័ង្ករបស់ទ្រង់ និង បរិវាររបស់ទ្រង់ ព្រះគម្ពីរក៏បានបង្ហាញថា នៅក្នុងស្ថាននៃវិញ្ញាណខ្មោងងឹត អារក្សក៏មានការរៀបចំរបស់វាផងដែរ។ មានអ្នកខ្លះបានកត់សំគាល់យ៉ាងមោះមុតថា សាតាំងគឺជា "ស្វា" ( ឬ "អ្នកធ្វើត្រាប់") តាមព្រះជាម្ចាស់។ សាតាំងមានបល្ល័ង្គ (គម្ពីរវិវរណៈ២:១៣)។ នៅក្នុងព្រះគម្ពីរ សាតាំងត្រូវបានគេហៅថា " ចៅហ្វាយរបស់លោកីយ៍" (គម្ពីរយ៉ូហាន១៤:៣០; ១៦:១១) និង " មេគ្រប់គ្រងរាជ្យលើអាកាស" (គម្ពីរអេភេសូ ២:២) ។ សាតាំងគឺជាមេគ្រប់គ្រងលើស្ថាប័នដ៏កំណាចមួយ។ ព្រះគម្ពីរបានថ្លែងថា សាតាំងមានទេវតារបស់វា (គម្ពីរម៉ាថាយ ២៥:៤១) ហើយទេវតាទាំងនេះប្រឆាំងជាមួយព្រះជាម្ចាស់ (គម្ពីរវិវរណៈ ១២:៧-៩) ។

ភស្តុតាងបន្ថែមទៀតអំពីស្ថាប័នដ៏កំណាចមួយនេះ ត្រូវបានលើកមកនិយាយនៅក្នុងលិខិតរបស់លោកប៉ូល ។ នៅក្នុងគម្ពីរកូឡុស ១:១៦ លោកនិយាយអំពី "រាជ្យ ឬអំណាចជាព្រះអម្ចាស់ ឬអំណាចគ្រប់គ្រង ឬអំណាច" ឯគម្ពីរអេភេសូ ៦:១២ ប្រាប់អំពី "ពួកគ្រប់គ្រង ពួកមានអំណាច និងពួកម្ចាស់នៃសេចក្តីងងឹតនៅលោកីយ៍នេះ..........អំណាចអាក្រក់ខាងវិញ្ញាណ នៅស្ថានដ៏ខ្ពស់ដែរ" ។ ទាំងអស់នេះ គឺដូចគ្នាជាមួយនឹង " ពួកគ្រប់គ្រង និងពួកមានអំណាច" ដែលព្រះគ្រិស្តបានយកឈ្នះដោយសារឈើឆ្កាង (គម្ពីរកូឡូស ២:១៥)។ នៅក្នុងបទគម្ពីរយោងទាំងនេះ យើងឃើញពីភស្តុតាងពីការរៀបចំទៅតាមឋានៈ

ដោយផ្អែកលើកម្រិតនៃអំណាច។ ការរៀបចំដ៏កំណាចនេះ ត្រូវបានរៀបចំឡើងដើម្បីប្រឆាំងទាស់ជាមួយព្រះអម្ចាស់យេស៊ូគ្រិស្ត ហើយធាតុផ្សំផ្សេងៗនៃអំណាចរបស់សាតាំងទាំងអស់នេះ ប្រកាន់គោលជំហរផ្ទុយពីព្រះជាម្ចាស់ និង ប្រជារាស្ត្ររបស់ទ្រង់។ យើងដឹងរឿងជាច្រើនអំពី ទេវតាមិនវិសុទ្ធ តាមរយៈការពិនិត្យទៅលើអ្នកដឹកនាំរបស់ពួកគេ។

## មេដឹកនាំរបស់ពួកគេ

ទេវតាមិនវិសុទ្ធ តែងតែទាស់ជាមួយព្រះជាម្ចាស់ ហើយព្យាយាមបំផ្លាញបំណងព្រះហឫទ័យរបស់ទ្រង់។ យើងឃើញពីភស្តុតាងនៃការនេះនៅក្នុងឈ្មោះដែលគេបានដាក់ឲ្យមេដឹកនាំរបស់ពួកគេៈ

១. មេដឹកនាំនោះត្រូវបានគេហៅថា *សាតាំង* ដែលមានន័យថា *បច្ចាមិត្រ* ឬ *គូរបដិបក្ស*។ សាតាំងគឺជាបច្ចាមិត្រជាចំបងរបស់*ព្រះជាម្ចាស់*។ គេក៏ជាបច្ចាមិត្ររបស់*មនុស្សជាតិ* ផងដែរ (គម្ពីរសាការី ៣:១ គម្ពីរម៉ាថាយ ១៣:៣៩ គម្ពីរ១ពេត្រុស ៥:៨)។

២. គេត្រូវបានហៅថា *អារក្ស ឬ មារ* ដែលមានន័យថា *អ្នកមូលបង្កាច់គេ* (អ្នកដែលធ្វើការចោទប្រកាន់មិនពិតត្រឹមត្រូវ ទាស់ជាមួយនឹងនរណាម្នាក់ ) ។ គេមូលបង្កាច់ព្រះជាម្ចាស់ទៅកាន់មនុស្ស (គម្ពីរលោកុប្បត្តិ ៣:១-៤) និង មូលបង្កាច់មនុស្សទៅកាន់ព្រះជាម្ចាស់ (គម្ពីរយ៉ូប ១:៩ ,១៦ គម្ពីរវិវរណៈ ១២:១០) ។

៣. ដោយសារតែ គេបញ្ឆោតចិត្ត (ល្បួង)មនុស្សឲ្យធ្វើអំពើបាប គេត្រូវបានហៅថា *អ្នកល្បួង*។ វិធីសាស្ត្ររបស់គេគឺ ការបង្ហាញឲ្យឃើញពីការដោះសារដ៏សមហេតុសមផលបំផុតសម្រាប់អំពើបាប ក៏ដូចជាផលប្រយោជន៍ដ៏អស្ចារ្យដែលសង្ឃឹមថានឹងទទួលបានការធ្វើអំពើបាបនោះ (គម្ពីរម៉ាថាយ ៤:៣ គម្ពីរ១ថែស្សាឡូនិក ៣:៥)។

ដោយសារតែសាតាំងមានដែនកំណត់ ហើយគ្មានឫទ្ធានុភាពគ្រប់ទាំងអស់ ដឹងគ្រប់យ៉ាង ឬ មានវត្តមាននៅគ្រប់ទីកន្លែងបាន វាប្រើប្រាស់មធ្យោបាយផ្សេង ដើម្បីទាស់ប្រឆាំងជាមួយព្រះជាម្ចាស់។ ប្រាកដណាស់ វាមិនអាចវាយប្រហារព្រះជាម្ចាស់បានដោយផ្ទាល់នោះទេ ដូច្នេះហើយវាក៏វាយប្រហារមនុស្សដែលជាស្នាព្រះហស្តដ៏ល្អក្រៃលែងរបស់ព្រះជាម្ចាស់ តាមរបៀបជាច្រើនៈ

- វាកុហក (គម្ពីរយ៉ូហាន ៨:៤៤ គម្ពីរ២កូរិនថូស ១១:៣)
- វាល្បួង (គម្ពីរម៉ាថាយ ៤:១)
- វាលួច (គម្ពីរម៉ាថាយ ១៣:១៩)
- វាធ្វើទារុណកម្ម (គម្ពីរ២កូរិនថូស ១២:៧)
- វារារាំង (គម្ពីរ១ថេស្សាឡូនិក  ២:១៨)
- វារែង (បែកចែក ច្រោះ) (គម្ពីរលូកា ២២:៣១)
- វាក្លែងបន្លំ ដើម្បីធ្វើការបំភាន់ (គម្ពីរ២កូរិនថូស ១១:១៤)
- វាចោទប្រកាន់ (គម្ពីរវិវរណៈ ១២:១០)
- វាធ្វើទុក្ខបុកម្នេញជាមួយជំងឺ (គម្ពីរលូកា១៣:១៦)
- វាចូលសណ្ឋិត (គម្ពីរយ៉ូហាន១៣:២៧)

- វាសម្លាប់ រួចលេបត្របាក់ (គម្ពីរយ៉ូហាន៨:៤៤ គម្ពីរ១ពេត្រុស ៥:៨)

ដូចដែលយើងបានឃើញហើយថា សាតាំងគ្រប់គ្រងទេវតាអាក្រក់ជាច្រើន ដែលបានចូលរួមជាមួយវានៅពេលដែលវាបះបោរប្រឆាំងនឹងព្រះជាម្ចាស់។ បើមើលទៅហាក់បីដូចជា ព្រះជាម្ចាស់បានអនុញ្ញាតឲ្យវារក្សាអំណាចដែលវាទទួលបាននៅក្នុងពេលដែលទ្រង់បង្កើតវាឡើងមក។ ពួកទេវតាមិនវិសុទ្ធដែលបានជ្រើសរើសដើរតាមវា ដោយមិនរក្សាសិទ្ធិអំណាចរបស់ពួកគេ និង ជម្រកដែលព្រះជាម្ចាស់បានប្រទានឲ្យ(គម្ពីរយូដាស៦) និង មិនបន្តស្មោះត្រង់ជាមួយនឹងព្រះអាទិកររបស់ពួកគេ គឺត្រូវបានបង្ហាញឲ្យឃើញច្បាស់តាមរយៈការបះបោររបស់ពួកគេ។ ពួកគេបានផ្តល់ភក្តីភាពរបស់ពួកគេទាំងស្រុងទៅដល់មេដឹកនាំរបស់ពួកគេ ហើយពួកគេសុខចិត្តផ្តល់ការបម្រើរបស់ពួកគេ ដើម្បីជួយវាឲ្យសម្រេចបាននូវបំណងដ៏អាក្រក់របស់វា។

## លំហាត់អនុវត្តន៍

១១ ចូរផ្គូផ្គងពាក្យ ឬ ឈ្មោះ (ខាងស្តាំ) ទៅជាមួយនឹងសេចក្តីរៀបរាប់របស់ពាក្យនោះ (ខាងឆ្វេង)។

| | |
|---|---|
| .........ក) ជាគោលដៅនៅក្នុងការវាយប្រហាររបស់អារក្ស ឬ ជាមធ្យោបាយដែលវាអាចសងសឹកព្រះជាម្ចាស់។ | ១) សាតាំង |
| .........ខ) ជាអ្នករួមចំណែកជាមួយអារក្ស នៅក្នុងការប្រយុទ្ធទាស់ប្រឆាំងជាមួយព្រះជាម្ចាស់។ | ២) មារ ឬ អារក្ស |
| ..........គ) ផ្តល់ឲ្យឃើញពីគំនិតអំពីបច្ចាមិត្ត ឬ អ្នកទាស់ប្រឆាំង។ | ៣) អ្នកល្បួង |
| ..........ឃ) ឈ្មោះដែលបានដាក់ឲ្យអ្នកដែលបញ្ឆោតចិត្តអ្នកផ្សេងមួយទៀតឲ្យធ្វើអំពើបាប។ | ៤) មនុស្សជាតិ |
| ...........ង) ឈ្មោះដែលត្រូវបានដាក់ឲ្យអ្នកដែលមូលបង្កាច់អ្នកដទៃ។ | ៥) ទេវតាអាក្រក់ |

## សកម្មភាពរបស់ពួកគេ

ទេវតាមិនវិសុទ្ធទាស់ប្រឆាំងនឹងព្រះជាម្ចាស់ មនុស្សរបស់ទ្រង់ ព្រមទាំងកិច្ចការរបស់ទ្រង់ ដោយដើរតួជាផ្នែកយោធា (ប្រយុទ្ធ) នៃអាណាចក្រដ៏ខ្មៅងងឹតរបស់សាតាំង (គម្ពីរម៉ាថាយ ២៥:៤១ គម្ពីរអេភេសូ ៦:១២ គម្ពីរវិវរណៈ១២:៧-១២)។ មានមនុស្សខ្លះព្យាយាមបែងចែកឲ្យដាច់ពីគ្នា រវាងវិញ្ញាណទេវតាមិនវិសុទ្ធ នឹង អារក្ស ឬ មារ ប៉ុន្តែគ្មានភស្តុតាងណាមួយដែលបង្ហាញថា ភាវៈទាំងពីរនេះមិនមែនជាភាវៈតែមួយ និង ជារបស់តែមួយនោះទេ។

ទេវតាទាំងនេះព្យាយាមបំបែកប្រជារាស្ត្ររបស់ទ្រង់ចេញពីទ្រង់ (គម្ពីររ៉ូម ៨:៣៨) ។ ពួកគេទាស់ប្រឆាំងជាមួយនឹងទេវតាដ៏វិសុទ្ធ (គម្ពីរដានីយ៉ែល ១០:១២-១១:១) ធ្វើទុក្ខមនុស្សដោយជំងឺខាងផ្លូវកាយ និងផ្លូវចិត្ត (គម្ពីរម៉ាថាយ ៩:៣៣;១២:២២ គម្ពីរម៉ាកុស៥:១-១៦ គម្ពីរលូកា ៩:៣៧-៤២) ផ្សព្វផ្សាយសេចក្តីបង្រៀនមិនពិត (គម្ពីរ២ថេស្សាឡូនិក ២:១-១២ គម្ពីរ១ធីម៉ូថេ៤:១) និង សណ្ឋិតក្នុងមនុស្ស ហើយសូម្បីតែសត្វទៀតផង (គម្ពីរម៉ាថាយ ៤:២៤ គម្ពីរម៉ាកុស៥:៨-១៤ គម្ពីរលូកា ៨:២ គម្ពីរកិច្ចការ ៨:៧; ១៦:១៦)។

ទោះបីជាពួកទេវតាមិនវិសុទ្ធមិនចង់ក៏ដោយ ពេលខ្លះព្រះជាម្ចាស់ប្រើប្រាស់ពួកគេ ដើម្បីសម្រេចបំណងព្រះហឫទ័យរបស់ទ្រង់ក្នុងការដាក់ទោសអ្នកមិនគោរពកោតខ្លាចព្រះជាម្ចាស់ (គម្ពីរទំនុកតម្កើង ៧៨:៤៩ គម្ពីរ១ពង្សាវតាក្សត្រ ២២:២៣) និង នៅអប់រំ និង ណែនាំមនុស្សល្អ (គម្ពីរយ៉ូប ១-២ គម្ពីរ១កូរិនថូស ៥:៥)។

## វាសនារបស់ពួកគេ

ពួកទេវតាមិនវិសុទ្ធ ជួយនៅក្នុងការបង្ហាញពីអ្វីដែលនឹងកើតឡើងទៅលើអស់អ្នកអសីលធម៌។ ភស្តុតាងបទគម្ពីរខាងក្រោមនេះ រៀបរាប់អំពីវាសនារបស់ពួកគេ ៖

- អារក្សដែលសណ្ឋិតនៅក្នុងបុរសពីរនាក់ បានស្រែកទៅកាន់ព្រះយេស៊ូថា៖ "ព្រះបុត្រារបស់ព្រះជាម្ចាស់អើយ! តើព្រះអង្គចង់ធ្វើអ្វីយើងខ្ញុំ? ព្រះអង្គយាងមកទីនេះ ដើម្បីធ្វើទុក្ខទោសយើងខ្ញុំ មុនពេលកំណត់ឬ?" (គម្ពីរម៉ាថាយ ៨:២៩)។
- ព្រះយេស៊ូបានមានព្រះបន្ទូលអំពី " ភ្លើងដែលឆេះអស់កល្បជានិច្ច ជាភ្លើងបម្រុងទុកសំរាប់ផ្ដន្ទាទោសមារ*សាតាំង និងបរិវារ(ទេវតា)របស់វា" (គម្ពីរម៉ាថាយ ២៥:៤១)។
- លោកប៉ូលបានប្រាប់យើងថា៖ " វានឹងចេញមុខមក ហើយព្រះអម្ចាស់យេស៊ូនឹងបំផ្លាញវាដោយខ្យល់ដែលចេញពីព្រះឱស្ឋរបស់ព្រះអង្គរួចហើយ នៅពេលព្រះអង្គយាងមក ព្រះអង្គនឹងជាន់កំទេចវា ដោយរស្មីរុងរឿងរបស់ព្រះអង្គ។" (គម្ពីរ២ថេស្សាឡូនិក ២:៨)។
- លោកយ៉ាកុបបានមានប្រសាសន៍ថា៖ "ពួកអារក្សក៏ជឿដូច្នេះដែរ ហើយថែមទាំងភ័យញាប់ញ័រទៀតផង" (គម្ពីរយ៉ាកុប ២:១៩)។
- លោកយ៉ូហានបានមានប្រសាសន៍៖ "ដ្បិតមារ*បានចុះទៅរកអ្នករាល់គ្នាទាំងមានកំរោលចូលយ៉ាងខ្លាំងផង ព្រោះវាដឹងថា វានៅសល់ពេលតែបន្តិចប៉ុណ្ណោះ"។ (គម្ពីរវិវរណៈ ១២:១២)
- លោកយ៉ូហាន មានប្រសាសន៍ថា៖ "គេនឹងរងទុក្ខវេទនាទាំងថ្ងៃ ទាំងយប់ អស់កល្បជាអង្វែងតរៀងទៅ។" (គម្ពីរវិវរណៈ ២០:១០)។

# លំហាត់អនុវត្តន៍

១២ ចូរអានបទគម្ពីរខាងក្រោម ហើយបំពេញប្រយោគខាងក្រោម។

ក) គម្ពីរ២ពេត្រុស ២:៤ ។ ដ្បិតព្រះជាម្ចាស់ពុំបានយោគយល់ដល់ពួកទេវតា*ដែលប្រព្រឹត្តអំពើបាបទេ ទ្រង់បានរុញពួកគេទម្លាក់ទៅក្នុង............. ដែល.................... ហើយគេជាប់ឃុំឃាំងនៅទីនោះ រង់ចាំពេលព្រះអង្គ..................។

ខ) យូដាស៦ ។ រីឯពួកទេវតា* ដែលពុំបានរក្សាឋានៈរបស់ខ្លួន តែបែរជាបោះបង់ចោលលំនៅរបស់ខ្លួន ផ្ទាល់ទៅវិញនោះ ព្រះជាម្ចាស់បានឃុំគេ.....................ហើយគេនៅជាប់ចំណងអស់កល្បជានិច្ច រង់ចាំថ្ងៃដ៏អស្ចារ្យដែលព្រះជាម្ចាស់នឹង........................។

គ) ទំនុកតម្កើង ៧៨:៤៩។ ព្រះអង្គដាក់ទោសពួកគេ អោយរងទុក្ខលំបាកយ៉ាងសែនវេទនា ដោយចាត់ពួក.....................ពួកគេ។

ឃ) គម្ពីរម៉ាថាយ៨:១៦ គម្ពីរម៉ាកុស ៩:២៥-២៦ ។ វិញ្ញាណអាក្រក់....................ក្នុងមនុស្ស។

ង) គម្ពីរលូកា ១៣:១០-១៦ ។ វិញ្ញាណអាក្រក់អាច........................................................។

ច) គម្ពីរវិវរណៈ ១២:៧-១២ គម្ពីរអេភេសូ ៦:១២។ កន្លែងដែលសាតាំង និង ទេវតាមិនវិសុទ្ធធ្វើ សកម្មភាពគឺនៅ........................................................។

---

ចេញពីការសិក្សារបស់យើងទៅលើសកម្មភាព និង វាសនារបស់ពួកទេវតា យើងអាចទាញយកសេចក្តីសន្និដ្ឋានសំខាន់ខ្លះៗដូចជា៖

១. យើងមិនត្រូវភាន់ច្រលំទាក់ទងនឹងវិធីសាស្រ្តរបស់អារក្ស ហើយអនុញ្ញាតឲ្យវាបោកប្រាស់យើងបាន នោះឡើយ (គម្ពីរ២កូរិនថូស ២:១១)។ យើងមិនត្រូវអនុញ្ញាតឲ្យវា មានកន្លែងឈរជើងនៅក្នុងជីវិត របស់យើងឡើយ (គម្ពីរអេភេសូ ៤:២៧)។ ផ្ទុយទៅវិញ យើងត្រូវត្រៀមខ្លួនដើម្បីជំទាស់នឹងវា ដោយ ប្រើប្រាស់អាវុធក្រោះរបស់ព្រះជាម្ចាស់ (គម្ពីរយ៉ាកុប ៤:៧ គម្ពីរអេភេសូ ៦:១០-១៨)

២. យើងមិនត្រូវមើលស្រាលអំពីអារក្សឡើយ (គម្ពីរយូដាស៨-៩) ហើយក៏មិនត្រូវមើលងាយកម្រិត ដែលវាហ៊ានបំផ្លាញជីវិតខាងវិញ្ញាណរបស់អ្នកជឿនោះដែរ។ ម្យ៉ាងវិញទៀត យើងមិនគួរភ្លេចសោះ ឡើយថា ព្រះយេស៊ូបានយកឈ្នះលើសាតាំងនៅលើឈើឆ្កាងរួចទៅហើយ (គម្ពីរហេប្រឺ ២:១៤) និងមិនត្រូវភ្លេចថា យើងរស់នៅដោយជំនឿ ដែលផ្អែកទៅលើជ័យជំនះមួយនោះ។

៣. អំណាចរបស់សាតាំង និង ទេវតាមិនវិសុទ្ធរបស់វា គឺមានដែនកំណត់នៅក្នុងពេលវេលា និង មាន កម្រិតទៅតាមបំណងព្រះហឫទ័យដែលព្រះជាម្ចាស់អនុញ្ញាត្ត។ ពួកទេវតាទាំងនោះ មិនមាន អំណាចគ្រប់ទាំងអស់ មិនដឹងគ្រប់យ៉ាង និង មិនមានវត្តមាននៅគ្រប់ទីកន្លែងឡើយ។

៤. យើងមិនត្រូវកំណត់ថាជំងឺ និង គ្រោះធម្មជាតិ ជាអំពើរបស់អារក្ស និង ទេវតារបស់វាឡើយ លុះ ត្រាតែនេះត្រូវបានបើកបង្ហាញជាក់លាក់។ អំណាចរបស់ពួកគេចំពោះការអាក្រក់គឺមានពិតប្រាកដ តែនៅមានកម្រិត។

៥. ទោះបីជាពួកគេប្រឆាំងជាមួយព្រះជាម្ចាស់ ទ្រង់នៅតែបង្ខិតបង្ខំពួកគេឲ្យបម្រើតាមបំណងព្រះហឫទ័យរបស់ទ្រង់បាន។ នៅពេលដែលព្រះជាម្ចាស់ប្រើប្រាស់ទំនោរនៃការអាក្រក់របស់ពួកគេ ដើម្បីសម្រេចបាននូវបំណងព្រះហឫទ័យរបស់ទ្រង់ ទ្រង់*នឹង* ធ្វើការវិនិច្ឆ័យ និង ដាក់ទោសពួកគេនៅក្នុងពេលដែលបានកំណត់ណាមួយ។

៦. អំណាចនៃវិញ្ញាណអាក្រក់មកលើមនុស្សជាតិ គឺមិនឯករាជ្យលើឆន្ទៈរបស់មនុស្សនោះទេ។ វិញ្ញាណអាក្រក់មិនអាចប្រើប្រាស់អំណាចរបស់ពួកវាបាន ដោយគ្មានការអនុញ្ញាតពីមនុស្សបានឡើយ។ នេះមានន័យថា អ្នកជឿអាចជំទាស់នឹងអំណាចរបស់ពួកវា តាមរយៈការអធិស្ឋាន និង ជំនឿលើព្រះជាម្ចាស់! យើងមានសេចក្តីសន្យាដ៏ប្រាកដនេះ ពីព្រះបន្ទូលរបស់ព្រះជាម្ចាស់មក៖ "កូនចៅអើយ អ្នករាល់គ្នាកើតមកពីព្រះជាម្ចាស់ ហើយអ្នករាល់គ្នាបានឈ្នះព្យាការី*ក្លែងក្លាយទាំងនោះ ដ្បិតព្រះអង្គដែលគង់នៅក្នុងអ្នករាល់គ្នា ទ្រង់មានអំណាចធំជាងម្ចាស់លោកីយ៍នេះទៅទៀត។" (គម្ពីរ១យ៉ូហាន៤:៤)។

# *លំហាត់អនុវត្តន៍*

---

១៣ ចូរគូសរង្វង់នៅជុំវិញអក្សរដែលនៅខាងមុខប្រយោគនីមួយៗដែលត្រឹមត្រូវ។

ក) យើងឃើញពីភស្តុតាងនៃបំណងរបស់សាតាំងនៅក្នុងឈ្មោះដែលត្រូវបានដាក់ឲ្យវា។

ខ) ដោយសារតែសាតាំងមិនអាចវាយប្រហារព្រះជាម្ចាស់ដោយផ្ទាល់បាន វាប្រហារមនុស្ស ដើម្បីជាការសងសឹកព្រះជាម្ចាស់។

គ) អារក្សត្រូវបានបង្កើតឡើងដើម្បីឲ្យធ្វើជាអ្នកដឹកនាំទេវតាអាក្រក់ដែលបះបោរជាមួយនឹងព្រះជាម្ចាស់។

ឃ) ទេវតាមិនវិសុទ្ធត្រូវបានបង្កើនមកឲ្យមានអាក្រក់ ដោយស្នាព្រះហស្តរបស់ព្រះជាម្ចាស់។

ង) ទេវតាអាក្រក់ គឺគ្មានដែនកំណត់នោះទេ ហើយអាចធ្វើរឿងទាស់ប្រឆាំងនឹងនរណាក៏បានគ្រប់ពេលទាំងអស់។

ច) ព្រះជាម្ចាស់ អាចប្រើពួកទេវតាអាក្រក់ ដោយមិនចាំបាច់មានការយល់ព្រមពីពួកគេ ទៅតាមបំណងព្រះហឫទ័យរបស់ទ្រង់ ដើម្បីដាក់ទោសមនុស្សដែលមិនគោរពកោតខ្លាចព្រះជាម្ចាស់ ឬ អប់រំមនុស្សល្អ។

ឆ) មានទេវតាអាក្រក់ខ្លះ ត្រូវនៅជាប់ឃុំ រហូតដល់ថ្ងៃវិនិច្ឆ័យទោសរបស់ពួកគេ ហើយមានខ្លះទៀតនៅមានសេរីភាពដើម្បីធ្វើកិច្ចការតាមបំណងរបស់អារក្ស។

ជ) សាតាំង និង ទេវតារបស់វា ស្ថិតនៅជាប់ក្នុងដែនកំណត់ក្នុងពេលវេលា ហើយអាចលាតសន្ធឹងបានតែទៅតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់អនុញ្ញាតឲ្យតែប៉ុណ្ណោះ។

ឈ) យោងទៅតាមបទគម្ពីរ អ្នកជឿគឺត្រូវបានបំពាក់បំប៉នយ៉ាងគ្រប់គ្រាន់ដើម្បីប្រឆាំងជាមួយនឹងអារក្ស និង កម្លាំងរបស់វា ហើយក៏ត្រូវបានបង្គាប់ឲ្យធ្វើយ៉ាងដូច្នោះដែរ ។

ញ) អារក្សមិនអាចចូល អ្នកជឿបាន ដោយផ្ទុយពីចិត្តរបស់គេបានឡើយ។

# ការប្រឡងផ្ទាល់ខ្លួនឯង

**ត្រូវ/ខុស។** ចូរសរសេរអក្សរ ត នៅខាងមុខប្រយោគត្រឹមត្រូវ និង អក្សរ ខ នៅខាងមុខប្រយោគមិនត្រឹមត្រូវ។

........១ ទេវតា ត្រូវបានបង្កើតឡើង ជាភាវៈខាងឯវិញ្ញាណ។

........២ ទេវតាគ្រប់រូបគឺ ត្រូវបានបង្កើតមកឲ្យមានភាពវិសុទ្ធ។

........៣ ពួកទេវតា អាចត្រូវបានគេហៅថា ក្រុមមួយ ឬ ពូជអម្បូរមួយ។

........៤ ចំនួនដ៏ច្រើនសន្ធឹកសន្ធាប់នៃពួកទេវតា បង្ហាញឲ្យឃើញពីភស្តុតាងនៃការរៀបចំ ដែលហាក់បីដូចជា ផ្អែកទៅលើការងារ ឬ កិច្ចការនៃក្រុមនីមួយៗ។

........៥ ទេវតាដែលចុះចោលឋានៈរបស់គេ និង ចាកចេញពីទីលំនៅរបស់គេ បានធ្វើដូច្នេះដោយជម្រើសផ្ទាល់ខ្លួនរបស់ពួកគេ។

........៦ ទេវតាមានភាពជាបុគ្គល មានសតិបញ្ញានិងអំណាចលើសពីមនុស្ស។

........៧ ទេវតាភាគច្រើនគឺមានសព្វញ្ញូតភាព សព្វដ្ឋភាព និង សព្វានុភាព។

........៨ ព្រះគម្ពីរបានបញ្ជាក់ថា ការធ្លាក់ចុះរបស់សាតាំងគឺជាលទ្ធផលនៃភាពក្រអឺតក្រទម ឬ អំនួតរបស់គេ។

.........៩ មានភស្តុតាងត្រូវបានលើកឡើង ដើម្បីគាំទ្រវត្តមានរបស់មហាទេវតា ចេរូប៊ីន សេរភីម និង ទេវតាជាច្រើនផ្សេងទៀតដែលគ្មានតំណាងសំខាន់។

........១០ អំណាចរបស់សាតាំងគឺមានដែនកំណត់នៅក្នុងពេលវេលា ហើយអាចលាតសន្ធឹងបានទៅតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់អនុញ្ញាត។

.......១១ ព្រះគម្ពីរបានថ្លែងថា យ៉ាងហោចណាស់មានទេវតា ពាក់កណ្តាល បានសម្រេចចិត្តដើរតាមសាតាំង ដូច្នេះក៏ត្រូវបានធ្លាក់ចុះជាមួយវា។

........១២ អារក្សអាចធ្វើការល្បួងយើងដើម្បីឲ្យយើងធ្លាក់ចុះបាន ប៉ុន្តែវាមិនអាចធ្វើឲ្យយើងឲ្យធ្លាក់ចុះបានឡើយ។

........១៣ មនុស្សអាចត្រូវអារក្សចូល ទាស់នឹងឆន្ទៈរបស់គេបាន ទោះបីជាពួកគេប្រឆាំងនឹងវាក៏ដោយ។

.........១៤ ព្រះគម្ពីរបានបង្ហាញថា មានទេវតាយ៉ាងច្រើនសន្ធឹកសន្ធាប់ ដែលពួកគេបង្កើតបានជាកងពលមួយដែលមិនអាចកំណត់ចំនួនបាន។

........១៥ ពាក្យថា ទេវតា មានន័យថា "អ្នកនាំសារ" និង រៀបរាប់ពីកិច្ចការដ៏ចម្បងមួយរបស់ពួកទេវតា។

# ចម្លើយសម្រាប់លំហាត់អនុវត្តន៍

៧ ខ) មានទេវតាជាច្រើនរាប់មិនអស់ ទាំងល្អនិងអាក្រក់ ។

១ ក) អ្វីៗសព្វសារពើ , ទាំងអ្វីៗដែលមើលឃើញ ទាំងអ្វីៗដែលមើលមិនឃើញ។

ខ) ជីវិត

៨ ក) ថ្វាយបង្គំ និង សរសើរតម្កើងព្រះជាម្ចាស់ ហើយធ្វើតាមបំណងព្រះហឫទ័យរបស់ទ្រង់។

ខ) បម្រើអ្នកដែលត្រូវប្រោសលោះ នៅលើផែនដី ក្នុងនាមជាវិញ្ញាណដែលចាំបម្រើ។

ឃ) ការពារ រំដោះ ដឹកនាំ លើកទឹកចិត្ត និង ផ្តល់កម្លាំងឲ្យមនុស្សរបស់ព្រះជាម្ចាស់។

ង) ដើរតួជាភ្នាក់ងារនៃការវិនិច្ឆ័យទោស និងការដាក់ទោសសត្រូវរបស់ព្រះជាម្ចាស់។

២ ខ) ភាវៈមានជីវិតអមតៈ ដែលនឹងមិនបាត់ទៅណានោះទេ។

៩ ក) ៦) ពួកពិនិត្យត្រួតមើល

ខ) ២) កាព្រីយ៉ែល

គ) ៤) ចេរូប៊ីន

ឃ) ៧) សត្វមានជីវិត

ង) ៣) ពួកទេវតាដ៏វិសុទ្ធ

ច) ៥) សេរភីម

ឆ) ១) មីកែល

៣ ពួកលោកមិនដឹងគ្រប់យ៉ាង មិនមានឫទ្ធានុភាពគ្រប់ទាំងអស់ និង មិនមានវត្តមាននៅគ្រប់ទីកន្លែងនោះទេ។

១០ ខ) គឺជាអ្នកបម្រើពិសេសនៅក្នុងឧបការគុណរបស់ព្រះជាម្ចាស់។

គ) បានបង្ហាញពីឫទ្ធានុភាពដ៏អស្ចារ្យ នៅពេលផ្តល់ក្រឹត្យវិន័យ។

ឃ) មានវត្តមាននៅពេលព្រះជាម្ចាស់បង្កើតពិភពលោក។

ឆ) ចូលរួមជាពិសេសនៅក្នុងការការផ្លាស់ប្តូរដ៏សំខាន់នៅក្នុងផែនការនៃការសង្គ្រោះរបស់ព្រះជាម្ចាស់។

៤ ក) ៤) គ្មានភេទ

ខ) ៧) គ្មានសព្វជ្ញភាព

គ) ៦) មានឫទ្ធានុភាពខ្ពស់

ឃ) ៥) មានសតិបញ្ញា

ង) ២) ជាវិញ្ញាណ

ច) ១) ត្រូវបានបង្កើតឡើង

ឆ) ៨) មិនមែនជាមនុស្សដែលមានសិរីល្អនោះទេ។

ជ) ៣) មានភាពជាបុគ្គល

១១ ក) ៤) មនុស្សជាតិ
ខ) ៥) ទេវតាអាក្រក់
គ) ១) សាតាំង
ឃ) ៣) អ្នកល្បួង
ង) ២) មារ ឬ អារក្ស
៥ ក) មិនកាន់តាមសេចក្តីពិត
ខ) ប្រព្រឹត្តិអំពើបាប
គ) ឋានះរបស់ខ្លួន, បោះបង់ចោលលំនៅរបស់ខ្លួនផ្ទាល់ទៅវិញ
ឃ) ការអួតបំប៉ោង (ដែលមានន័យថា មោទនភាពជ្រុល)
១២ ក) នរកអវិចី , ងងឹតសូន្យ, វិនិច្ឆ័យទោស
ខ) ទុកក្នុងទីងងឹត, វិនិច្ឆ័យទោស
គ) ទេវតាអោយមកប្រហារ
ឃ) ចូលសណ្ឋិត
ង) ធ្វើឲ្យមនុស្សពិការ
ច) ស្ថានលើ និង ផែនដី
៦ ក) ២) អត្ថបទបញ្ជាក់
ខ) ១) គាំទ្រច្បាស់ៗ
គ) ២) អត្ថបទបញ្ជាក់
ឃ) ៣) មិនគាំទ្រសោះ
ង) ២) អត្ថបទបញ្ជាក់
ច) ១) គាំទ្រច្បាស់ៗ
ឆ) ១) គាំទ្រច្បាស់ៗ
ជ) ៣) មិនគាំទ្រសោះ
ឈ) ១) គាំទ្រច្បាស់ៗ
ញ) ៣) មិនគាំទ្រសោះ
១៣ គ), ឃ), និង ង) គឺមិនត្រឹមត្រូវទេ។ ឯចម្លើយផ្សេងទៀតដែលនៅសល់គឺសុទ្ធតែជាចម្លើយត្រឹមត្រូវ។